# សៀវភៅគតិលោក

## ភាគ ទី៥



សុត្តន្តប្រិជា ឥន្ទ

១៨៥៩ - ១៩២៤

CHANBOKEO.COM
ឆែន បន្ទុះឈាន

# និទាននេះមានដំណាលក្នុងកម្ពុជបាវាំងសែស

មានសត្វចចក១ ទៅសុំទុងជាមិត្រ ទុងនោះសោតក៏មានចិត្តស្រឡាញ់ចចកជាមិត្រមែត្រី ប៉ុន្តែសត្វទាំងពីរនោះជាសត្វទាំងពីរនោះ ជាសត្វស្រឡាញ់គ្នាតែកិរិយាខាងក្រៅ ឯក្នុងចិត្តនោះ គិតតែងកោងគ្នាដោយក្តីមច្ឆរិយ:កំណាញ់ទបស់ទៀងខ្លួន ។ ថ្ងៃមួយចចកនិយាយបបួលទុងថា "មិត្រអើយ! ថ្ងៃនេះខ្ញុំសូមអញ្ជើញមិត្រឯងទៅស៊ីលៀងនៅផ្ទះខ្ញុំតាមកាល" ទុងក៏ព្រមទៅ។ មុននឹងទៀបភោជនាហារលៀងនោះ ចចកគិតថា "អញនឹងមិនឲ្យអាទុងវាចឹកស៊ីរបស់អញបាន" គិតហើយចចកទៀបបាយចំណីដាក់ក្នុងភាជនៈ មានផ្ទៃរាបប្រៀបដូចថាសរាប ហើយប្រាប់ទុងថា "អញ្ជើញមិត្រពីសាឲ្យសបា្បយ" ឯទុងជាសត្វចំពុះវែង ចឹកចំណីអាស្រ័យពុំបានដោយទើសនឹងថាសរាបវឹង ម្ល៉ោះហើយក៏ឈប់ឈរ នៅស្ងៀមទៅឯចចកមាត់វាទាលវាស៊ីបាន ស៊ីបណ្តើរនិយាយថា "ម្តេចសំឡាញ់មិនពិសារទៅ" ទុងស៊ីពុំបាន ឯចចកក៏ចេះតែស៊ីទាល់តែឆ្អែតហោង។

ឯទុងនោះ កាលវួចការស៊ីលៀងហើយក៏ហើរមកកាន់លំនៅនៃអាត្មា តើតក្តៅចិត្តនឹងចចកទៀបអាហារដាក់មិនឲ្យខ្លួនស៊ី



បាន ទើបគិតថា "ចាំអញទៅបបួលអាភ្សើនកោងមកស៊ីលៀងនៅផ្ទះអញវិញ អញនឹងទៀបអាហារចំណីដាក់ កុំឲ្យអាចចកនោះវាស៊ីបាន" គិតហើយទៅបបួលចចកមកស៊ីលៀងនៅផ្ទះអាត្មាចចកក៏មក។ ទុងក៏ទៀបអាហារចំណីនោះ ដាក់ក្នុងដបមានមាត់តូច ដែលខ្លួនអាចបញ្ចូលចំពុះទៅក្នុងដបចឹកយកចំណីបាន ហើយហៅទៅចចកថា "អញ្ជើញមិត្រចូលពីសាជាមួយគ្នាទៅ" ឯចចកនោះមាត់ធំលូកមិនចុះទៅក្នុងដបនោះទៀ្យ រកឱកាសនឹងស៊ីពុំបាន ក៏អង្គុយស្ងៀមនៅ គិតឃើញថាទុងគេកែខ្លួនគេហើយ ព្រោះពីថ្ងៃមុន ឯងក្តែងដាក់អាហារនឹងថាសរាប មិនឲ្យវាស៊ីបាន ឥឡូវវាក្តែងដាក់អាហារក្នុងដបមាត់តូចដល់វួចការលៀង ក៏លាទុងវិលទៅកាន់លំនៅនៃខ្លួនវិញហោង។

ទៀងនិទាននេះ មានគតិប្រៀបដូចម្តេចចូរឯងប្រៀបប្រាយទៅមើល។

កូនសិស្សតបថា ទៀងនេះបានគតិខាងមិត្តតែមាត់ចិត្តមិនបានជាមិត្តទៀ្យ ឯកិរិយាក្តែងពុំចង់ឲ្យភ្សើនឬភ្សៀវអាស្រ័យនោះ ដូចអ្នកខ្លះទៀបបាយឲ្យភ្សៀវបរិភោគដាក់ស្វាយទុំទាំង

មូលតែកាំបិតពុំបានដាក់ឲ្យចិតទេ្បីយ ឬមួយដាក់ហឹបស្លាឲ្យស្ទុះ
ដាក់ស្លាស្លឹងទាំងមូល តែប្រណាកពុំដាក់ យ៉ាងនេះឲ្យចូលចិត្តថា
ដូចតម្រាទុងនឹងចចកនេះឯង ។

**ចប់តម្រាគតិមិត្រកោងមិត្រទី៨**

## និទាននេះមានដំណាលក្នុងក្បួនបាវាំងសែស

មានសត្វទុង១ ជាសត្វកាន់សក្តាយទិដ្ឋិ ថ្ងៃមួយចេញស្វែងរក
ចាប់ត្រីជាអាហារ លុះហែលទៅបានឃើញត្រីក្អែត១ ហែល
នៅខាងមាត់ខ្លួនទុងនោះក៏ចឹកត្រីក្អែតនោះបាន ទើបមកគិតថា
អាត្មាអញនេះជាបក្សីរូបធំ ត្រូវតែបរិភោគត្រីធំៗយ៉ាងត្រី
រស់ ត្រីឆ្ពោ ត្រីប្រាជាដើមនោះ ទើបសមនឹងសិក្ខាយសរូប
អញនេះ អាត្រីក្អែតរូបតូចមួយនេះ មិនសមគួរនឹងរូបអញ
ទេ្បីយ គិតហើយទុងក៏លែងចោលត្រីក្អែតនោះបង់ហើយហែល
ទៅមុខទៀត លុះដល់ទី១ បានឃើញត្រីចង្ហា ១ ហែលមកខាង
មុខ ទុងនោះចឹកបានលើកទេ្បីងគិតទៀតថា ត្រីចង្ហានេះក៏តូច
ណាស់ពុំសមគួរនឹងអញជាបក្សីធំនេះទេ្បីយ គិតហើយក៏លែង
ត្រីចង្ហានោះចោលបង់ ហើយហែលទៅមុខទៀតបានឃើញត្រី
ចង្ហាស្វៃង១ ទុងក៏ចឹកបានលើកទេ្បីងនឹងស្ទុះ ក៏គិតថាត្រីចង្ហាន



ស្វៃងនេះ រូបតូចពេកណាស់ពុំគួរនឹងរូបអញជាធំគិតហើយក៏
លែងត្រីនោះចោលបង់ ហើយខំហែលទឹកស្វែងទៅមុខទៀត
ស្វែងទៅៗរកត្រីពុំបាន ពេលសោតក៏ទន់ទាបល្ងាចនឹងផុតពេល
ស្វែង ទុងនោះឯងកើតឃ្លានអាហារមហិមាខំស្វែងរកអាហារពុំ
បានទេ្បីយ ម្ល៉ោះហើយទុងកើតទុកខមុខសុបសៅ កើតក្តៅចិត្ត
គិតស្តាយអាហារដែលខ្លួនរកបានអំពីព្រឹកនោះថា ស្តាយអើយ
សែនស្តាយត្រីក្អែត១ នោះបើប្រសិនជាបរិភោគមកល្មមកល់ខ្លះ
ស្តាយត្រីចង្ហា បើប្រសិនណាជាស៊ីមកក៏ជាការកល់ទេ្បីងរួមនឹង
ត្រីក្អែតជាន់មុននោះ ស្តាយត្រីចង្ហាស្វៃងមួយ បើប្រសិនណាជា
ស៊ីមកទៀត ក៏ជាការផ្សំគ្នានឹងត្រីជាន់មុនបានកល់ទេ្បីងច្រែន
ល្មមបន្ទោបង់ក្តីឃ្លាននេះបាន ឥឡូវនេះដល់ពេលឃ្លានក៏ខ្លាំង
ពេលថ្ងៃនឹងស្វែងទៅទៀត ក៏ផុតតែត្រីមនេះ អញនេះហៅ
ពេញជាគិតខុស មិនសន្សំត្រីតូចៗស៊ីផ្សំគ្នាគិតប្រមាថថាអា
តូចៗមិនសមនឹងខ្លួន ចាំរកត្រីធំៗឲ្យសមសិក្ខាយសខ្លួន ដល់មិន
បានត្រីធំក៏អត់ទៅតម្រានេះ គឺអាធំក៏ខូច អាតូចក៏ខាត បានក្តី
ទុក្ខទៀនាដោយអត់អាហារនោះហោង ។

អើទេ្បីងនេះបានជាគតិប្រៀបប្រាយទៅយ៉ាងណាឯងថា

ទៅមើល ។

កូនសិស្សតបថា គតិនេះបានដូចកូនអ្នកកាន់ត្រកូលទៅ
ទៀនទិដ្ឋាចេះមកអំពីប្រទេសក្រៅ ហើយចូលមកប្រទេសខ្លួន
រាជការបានតាំងឲ្យធ្វើការបើកប្រាក់ខែឲ្យត្រឹម ១០ ២០ទៀល
ជាដើម ខ្លួនមិនទទួលធ្វើកាន់ខ្លួនថា ខ្លួនជាកូនត្រកូលធំ ប្រាក់ខែ
ប៉ុណ្ណឹងមិនសមនឹងចំណេះនឹងត្រកូលខ្លួន គតិចាំយកប្រាក់ខែដល់
៨០ ៩០ ឬ ១០០ ជាទុនធំតែម្តង ដូចទូងចាំយកត្រីរ៉ស់ ត្រីឆ្តោ
ពោប្រាតែម្តងដល់រកមិនបានតើតខាតខាន តើតស្តាយទុនតូច
ដែលគេបំទុងឲ្យក្នុងកាលមុននោះឯង ។

មួយទៀត បានដូចលោកចៅអធិការឬលោកមហា អាចារ្យ
កាន់ខ្លួនថាធំ គតិថាអាត្មានេះសមតែគៀនមន្តទ្បើងត្រែទេសនា
សង្គាយនា ឬឆាកមហាបង្សកុល ទស់បន្តូង ត្រែងកឋិន ក៏ឯការ
តូចៗដូចយ៉ាងគៀនមន្តសូត្រមន្ត ឬបង្សកុលខ្មោចជាដើមនេះ
មិនសមគួរដល់អាត្មាជាធំទ្បើយ កាន់ដូចយ៉ាងទុងនេះឯង ។

**ចប់តម្រាគតិរកស៊ីមិនសន្សំពីរតួតូចៗទី៨**

## និទាននេះមានដំណាលក្នុងក្បួនបាំងសែស

មានសត្វកណ្តុប ១ ហើរទៅទំស៊ីស្លឹកនូវផ្លែផ្តៅនៃដើមសន្ទែ



ដុះនៅទាលស្រែក្រៅ១ លុះបរិភោគឆ្អែតហើយ ក៏ហើរទៅ
ព្រៃភ្នំ ចុះទំលើមែកសន្ទែភ្នំ១ ដុះនៅក្រោមឈើធំទាំងឡាយ
លុះដល់ពេលឃ្លានអាហារក៏ហើរឆ្ងៀលដើមសន្ទែភ្នំ ដើមព្រីក
មើលស្លឹក មើលផ្លែផ្តៅនិងបរិភោគ ហើរទៅពុំឃើញមានស្លឹក
នូវផ្លែផ្តៅឃើញមានតែដើមខ្ចីស់ដូច្នោះ កណ្តុបនោះក៏និយាយថា
ដើមសន្ទែដែលដុះឯទៀលស្រែនោះ គេមានមែកត្រសុំត្រសាយ
បរិបូណ៌ដោយផ្លែផ្តៅ មានស្លឹកស្រោបជិតដុំដើម ជាទីប្រជុំនៃ
សត្វកន្លង់ កណ្តុប អណ្តើក មាសទាំងឡាយអាស្រ័យបរិភោគបាន
អើប្រសែ្តងសន្ទែភ្នំនេះ ហេតុអ្វីក៏ពុំមានស្លឹកបែកផ្លែផ្តៅដូចគេ
មានតែដើមដុះលូតខ្ចីស់ទៀងចុងយ៉ាងនេះ រកតែស្លឹកនឹងស្រោប
ខ្លួនគ្មាន ។

ឯសន្ទែនោះក៏ប្រាប់ថា "ឱអ្នកអើយ! ដើមខ្ញុំនេះដុះនៅ
ក្រោមឈើធំ ក៏ទីស័យឈើធំទាំងឡាយមានដើមផ្ងឹកវាំងឈើទាល
ជាដើមនោះ គេជាតិឈើភ្នំប្រកបដោយខ្លឹមខាងក្នុង គេក៏លូត
បែកមែកត្រសាយត្រសុំ ដោយភាពគេជាឈើភ្នំ តែខ្ញុំឯងនេះ
ជាជាតិឈើឥតខ្លឹម ហើយមកដុះនៅខាងគេ តាំងលូតតាមគេ
ទៅ ទាល់តែរកស្លឹកពុំមានយ៉ាងនេះឯង ។

ឯកណ្ឌប ក៏និយាយតិះដៀលដើមសន្ទែកនោះផ្សេងៗហើយ សរសើរដើមសន្ទែក ដែលដុះនៅតាមទាលស្រែផុតអំណាចឈើធំនៅគ្របសង្កត់ពីខាងលើ ពុំបានលូតតាម ត្រាប់តាមឈើធំឲ្យបង់ស្លឹកផ្ទៃផ្កាដុះតាមធម្មតាខ្លួនឯង តាមតែចិត្តចង់បំបែកមែកតូច ធំតាំងស្លឹកផ្កាផ្ទៃបិទបាំងខ្លួនយ៉ាងណាៗ ក៏ឥតមានទើសទាល់អ្វីមួយទៀត កណ្ឌបពោលពាក្យដូច្នោះហើយក៏ហើរទៅកាន់លំនៅនៃខ្លួនវិញ។

ចុះទៀងនេះ បានសេចក្តីជាគតិយ៉ាងណាចូរអត្ថាធិប្បាយទៅមើល?។

កូនសិស្សតបថា ឯដើមផ្ទឹកទាំងឈើទាលនោះ ជាវុក្ខជាតិមានខ្លឹម ដុះទៀងក៏លូតខ្ពស់តាំងបែកមែកតូចធំ ព្រមទាំងស្លឹកផ្ទៃផ្កាបាន សមដោយជាតិជាឈើធំ នេះបានគតិដូចមនុស្សអ្នកមានសម្បត្តិ មានយសសក្តិ មានប្រាក់ខែបរិបូណ៌បើគេស្លៀកពាក់ត្រៀងតែខ្លួន ឬគេបរិភោគភោជនាហារយ៉ាងឧត្តមក៏សមរបស់គេឥតមានក្តីខាត់ ឯជាតិដើមសន្ទែកឬប្រៃបួយ លាជដុះជាដើមនោះ ជាជាតិឈើស្រែ ឈើក្រៅ សមគួរតែដុះទាលស្រែក្រៅ ដែលផុតអំពីម្តប់ឈើធំ ទើបអាចតាំងមែកស្លឹកផ្ទៃ



ផ្កាបរិបូណ៌ទៅបានបើទៅដុះនៅខាងឈើធំហើយ ក៏ពុំអាចតាំងមែកស្លឹកផ្ទៃផ្កាបានទៀយ នេះបានគតិដូចមនុស្សអ្នកឥតចំណេះឥតទ្រព្យសម្បត្តិ ហើយត្រាប់តាមអ្នកមានសម្បត្តិ មានយស ទិសត្រៀងតែងខ្លួន ឬអាហារខ្ពស់ប្រៃក៏ទិយ៉ាងអ្នកធំលូតតាមអ្នកធំ ម្ល៉ោះហើយក្តីក្រក្តីលំបាក ក៏កើតដល់ប្រាណ មានឧបមេយ្យដូចដើមសន្ទែកត្រាប់តាមឈើធំនោះឯង។

ឯដើមសន្ទែក ដែលដុះដោយទាលស្រែបរិបូណ៌ដោយមែកស្លឹកផ្ទៃផ្កានោះ បានគតិដូចមនុស្សអ្នកឥតចំណេះវិជ្ជាការខ្វត់ក្រ តែទៅប្រព្រឹត្តដោយការរកស៊ុធ្វើស្រែចំការដួញប្រៃលក់ដូរ ឱសក្រាហិសន្សំទ្រព្យសម្បត្តិ ទុកដាក់ពុំហ៊ានចែកចាយដោយការពុំគួរចាយនោះ ទ្រព្យសម្បត្តិក៏តមានទៀង ដូចដើមសន្ទែកដុះដោយទាលស្រែនោះឯង។ អ្នកស្រែចំការមានទ្រព្យសម្បត្តិ ជាទីឲ្យមហាជនសរសើរ។

អ្នកក្រុងពិតតែឥតទ្រព្យសម្បត្តិ ប៉ុន្តែប្រឹងលូតតាមអ្នកធំដូចដើមសន្ទែកដុះកែ្បរភ្នំ ជាទីឲ្យកណ្ឌបមេរំបៅអណ្តើកមាសតិះដៀលនិន្ទា។ អ្នកមានបញ្ញាគួរពិចារណាយកជាគតិលោកយោគឲ្យឃើញមនុស្សត្រាប់អ្នកធំមាននៅក្នុងសម័យឥឡូវនេះ។

មានក្អែក១ បានឃើញខ្មោចឆ្កែ១ អណ្តែតទឹកក៏ចុះទំចឹក
ស៊ីបណ្តែតទៅតាមខ្សែទឹក ចេញទៅដល់កណ្តាលសាគរ ក្អែក
នោះភ្លើនស្មារតី ពុំបានគិតនឹងហើរទិលមកកាន់ទីគោកទៀយ ។
លុះស៊ីឆ្អែតហើយ ក្អែកនឹងគេចហើរមកទីគោកពុំបានព្រោះ
ខ្មោចឆ្កែនោះ អណ្តែតទៅកណ្តាលមហាគង្គា ផុតមើលត្រែយ
ពុំឃល់ ក្អែកនោះហើរមកមិនដល់គោក ក៏គាំងស្លាប់អស់កំលាំង
ធ្លាក់លិចចុះក្នុងគង្គា ដល់នូវក្តីមរណៈសូន្យជីវិតហោង ។
ទើងនិទាននេះ បានគតិប្រៀបប្រាយអត្ថាធិប្បាដូចម្តេច?
កូនសិស្សតបថា ទើងនេះបានគតិដូចនិទានសត្វចចកដែល
លោភខ្លាំង ចូលទៅស៊ីត្រើងក្នុងពោះនៃខ្មោចដ៏ទីសារ បាននូវ
សេចក្តីទុក្ខវេទនា ព្រោះឥតសតិបញ្ញានឹងពិចារណាឲ្យឃល់
ហេតុដល ហៅថាមិនដឹងប្រមាណក្នុងការបរិភោគភោជន អ្នក
ប្រាជ្ញគប្បីចូលចិត្តហោង ។

**ចប់តម្រោគតិលង់ដោយលោភទី ១០។**

មានលោកសង្ឃអង្គ១ ជាចៅអធិការ នាំក្មេងពីរនាក់ជាកូន
សិស្សចេញចាកអារាមទៅព្រៃ ដើមប្បីនឹងទំញើឈើធ្វើកុដិ
កូនសិស្សក៏ស្តាយកញ្ចប់ចង្ការយកទៅដើមប្បីឆាន់ពេលថ្ងៃត្រង់



លុះទៅដល់ត្រពាំង១ មានទឹកដ៏ថ្លាស្អាត មានទុក្ខជាតិដុះជិត
ជុំ ម្ខប់ត្រសុំសបា្បយ ជួនពេលថ្ងៃត្រង់លោកសង្ឃនោះ ចូល
ឈប់ប្រាទព្ធនឹងឆាន់បាយ ទើបក្មេងទាំង២ នាក់ ក៏ចាត់ចែងយក
ចង្ការកញ្ចប់នោះប្រគេន ឯម្ខបនោះមានតែត្រែកន្ត្រប់អាំង១ ។
លោកចៅអធិការក៏តាំងឆាន់ ឯក្មេងទាំង២ នាក់ទាអង្គុយគាល់
លោកឆាន់ ទានឹកក្នុងចិត្តទាថា លោកគ្រូប្រហែលជាឆាន់ត្រែកន្ត្រប់
នេះ តែ១ចំហៀងខាងលើឯចំហៀងខាងក្រោមសោត គង់តែ
លោកនឹងទុកឲ្យយើងកូនសិស្សពីរនាក់ ក្មេងគិតដូច្នោះហើយ
ទាក៏ខ្សឹបប្រាប់គ្នាទាឲ្យដឹងជាសញ្ញា ។
ឯលោកចៅអធិការ លុះឆាន់បាយអស់ត្រែអាំង១ ចំហៀង
ហើយក៏នៅឆ្ងាញ់ ទើបប្រែត្រឡប់ត្រែកន្ត្រប់ឆាន់ខាងចំ
ហៀងក្រោមទៀត ។
ឯកូនសិស្ស ឃើញលោកគ្រូត្រឡប់ត្រែអាំងឆាន់ចំណែក
ខ្លួនទាដូច្នោះ ទាក៏នាំគ្នាក្រោកឈរទៀងហើយទាថា ទុំយគ្នាយើង
ឥឡូវនេះផែនដីប្រែហើយនៅផងពុំបានទេ អាដែង ។
ក្នុងខណៈនោះមានក្របីព្រៃ១ ដើរមកផឹកទឹកក្រពាំង បាន
ឃើញមនុស្សនៅនោះ ទាក៏បោលចូលមកនឹងទីធ ។

ឯកូនសិស្សទាំងពីរនាក់បានឃើញក្របីព្រៃបោលដេញមក
ដូច្នោះ ទើបវានាំគ្នារត់ចោលលោកគ្រូ ហើយវាទៅឯដើមឈើ
ត្រាតែដល់ចុង ផុតអន្តរាយនឹងក្របី ឯលោកចៅអធិការកំពុង
តែឆាន់ឆ្វាញ់ស្រាប់តែក្របីព្រៃមកជិត ក៏ភិតភ័យតក់ស្លុត
ក្រោកទៅនឹងរត់ ហើយស្រែកហៅកូនសិស្សឲ្យជួយដោយ
ទួសានណាស់ ។

ឯកូនក្មេងនៅលើចុងឈើវានាំគ្នាស្រែកទៅថាផែនដីប្រែ
ហើយ នរណាទៅនឹងទៅជួយត្រឹកន្ត្រាប់តូចមួយ ឆាន់អស់នៅ
សល់តែឆ្អឹង ចូលលោកគ្រូខឹប្រឹងរត់ទៅតែឯង តាមយថាកម្ម
វៀងខ្លួនចុះយើងមិនចុះទៅជួយទេ ។

ឯលោកនោះ រត់មិនរួចពីក្របី ។ ក៏ទីធដល់នូវមរណកាល
កណ្តាលព្រៃនោះហោង ។

វៀងនិទាននេះ បានសេចក្តីជាគតិយ៉ាងណាចូរថាទៅមើល?

កូនសិស្សតបថា វៀងនិទាននេះបានគតិដូចពាក្យសុភាសិត
ច្បាប់ចាស់ថា "បានស្តូននឹងទឹកឃ្មុំពួនក្នុងផ្ទះស៊ីម្នាក់ ឯង" ។ បុគ្គល
ទាំងឡាយក្នុងលោកនេះ សឹងមានអាហារជាថ្នាំកែរោគឃ្លាន គឺ
តំណាងជារោគធំបំផុត បុគ្គលណាចង់រស់តែឯង មិនគិតដល់អ្នក



ដទៃផង បុគ្គលនោះលុះមានក្តីភ័យឯណាមួយមកដល់ខ្លួនហើយ
នឹងស្រែករកឲ្យគេជួយ គេក៏ពុំមកជួយទៀយហៅថាពុំដឹង
ប្រមាណក្នុងការបរិភោគ ។ អ្នកមានបញ្ញាគួរត្រិះរិះគិតទៅ
ទៀតចុះ ។

**ចប់តម្រាតិបរិភោគអាហារមិនគិតរកទី ១១**

**តម្រាប្រែផែនដីក្របីរវីធស្លាប់ អញ្ជើញអ្នកស្តាប់ កុំត្រាប់យកជាគតិ។**

និទានព្រះមហិសិ្សរាធិបតី គឺព្រះឥសូរសាងលោក កាលសាង
លោកសំរេចហើយ ព្រះឥសូរហៅពួកសត្វចតុប្បាទ អបាទ
ពហុបាទ ទាំងឡាយចូលមកកាន់ទីប្រជុំ ដើម្បីនឹងសួរសេចក្តីសុខ
ទុក្ខសព្វសត្វ តើសត្វពួកណា គាប់ចិត្តនឹងរូបកាយខ្លួនឬពុំគាប់ចិត្ត
នឹងរូបកាយខ្លួនទេ នឹងកែប្រែជាថ្មីតាមក្តីប្រាថ្នារបស់សត្វលោក
ទាំងពួង ។

កាលទ្រង់សួរនោះ គឺទ្រង់សួរស្វាជាមុនថា "ម្នែចៅពានរទូប
កាយបាឯងដែលយើងសាងឲ្យ មានអនិយរ:យ៉ាងនេះ សព្វថ្ងៃនេះ
តើចៅគាប់ចិត្តពេញចិត្តហើយឬ។ នៅមានក្តីទាល់ត្រង់ណាខ្លះ
ចូរចៅថាទៅមើលនឹងកែប្រែជាថ្មីទៀត" ។

ឯពានរមើលទោសឯងមិនយល់ សំគាល់ថារូបខ្លួនឥតទាស់

ទើបទូលព្រះឥសូរថា "សូមទានល្អងធូលីព្រះបាទសាងរូបកាយ
ខ្ញុំជាស្វានេះ ពេញជាស្រួលណាស់ហើយ មានទាំងដៃជើងទ្បើង
ដើមឈើបានកកបកំលាំង លោតចេះផ្លែឈើអាស្រ័យបានដោយ
ងាយ ទាំងឥតកិច្ចការធ្វើស្រែចំការជួញប្រែដូចយ៉ាងមនុស្ស
នោះទ្បើយ ព្រះអង្គសាងរូបកាយខ្ញុំនេះគាប់ចិត្តខ្ញុំហើយ មិន
បាច់កែប្រែឲ្យខ្ញុំទៀតទេ បើព្រះអង្គចង់កែនោះ សូមមេត្តា
តែសត្វខ្លាឃ្មុំទាំ្ង ព្រោះរូបវាមិនសមរម្យល្អទេ គឺមុខនោះ
ច្របូញ្ច ទោមខ្មៅជិត ឥតមានកន្ទុយនឹងបត់ ឃើញអាក្រក់លើ
សគេនានា សូមមេត្តាកែវាជាថ្មីចុះម្ចាស់"។ ព្រះឥសូរបានឮថា
ដូច្នោះក៏ត្រាស់ទៅខ្លាឃ្មុំថា "ម៉ែចចៅអច្ឆាជាតិ រូបកាយចៅឯង
ដែលយើងសាងឲ្យយ៉ាងនេះ តែជាទីគាប់ចិត្តចៅឯងហើយឬ។
នៅទាស់ត្រង់ណាខ្លះ ចូរថាមកយើងនឹងកែឲ្យ?"។

ឯខ្លាឃ្មុំមិនយល់ទោសខ្លួនក៏ឆ្លើយថា "រូបខ្ញុំនេះព្រះអង្គសាង
ឲ្យមានធ្មេញចង្កូមដ៏មុត ទាំងទោមខ្មៅជិតបិទសែ្បកក្នុង កុំឲ្យ
សត្វតូចៗ មានមូសស្រាំងស្រួយជាដើមចូលយាយីបាន ហើយមាន
ជើងទាំង៤ ប្រកបដោយក្រចកដ៏មុត អាចទ្បើងឈើព្រៃយក
ឃ្មុំអាស្រ័យជាភក្ដាហារបាន ឥតមានក្តីកង្វល់ទន់ល់ដោយការ



ធ្វើស្រែចំការ ដូចមនុស្សក្នុងលោកនេះទ្បើយ រូបខ្ញុំនេះពេញ
ចិត្តខ្ញុំហើយ មិនបាច់កែទៀតទេ បើព្រះចង់កែ សូមកែរូបដ៏ទ
ទៀតចុះ ដ្បិតរូបដ៏ទនោះខ្ញុំយល់ថាទាស់ខ្លាំងណាស់ គឺរូបអីមាន
ប្រមោយ១ កន្ទាលធំភ្នែកតូច ត្រចៀកកំភ្លាងរូបរាងធំកោង
មើលមិនសមសោះម្ចាស់"។

ព្រះឥសូរឮអច្ឆាថាដូច្នោះ ក៏សួរទៅកាន់ដំរីទៀតថា "ចៅ
ហត្ថ រូបកាយចៅដែលយើងសាងឲ្យយ៉ាងនេះតើគាប់ចិត្តចៅ
ហើយឬ។ នៅទាស់ត្រង់ណាទៀត ចូរថាទៅមើល?"។

ឯដំរីពុំយើញទោសខ្លួន ទើបសួរថា "ព្រះអង្គសាងរូបខ្ញុំឲ្យ
មានកាយធំខ្ពស់លើសគេ ទាំងភ្លុកសោតក៏ល្អប្រើជាអាវុធបាន
ទាំងកំលាំងហៅហាន អាចចាក់អាចព្រៃចន្ទវិសត្ថវិឥតទើស
ទាល់ បរិភោគស្មៅជាអាហារ ឥតក្តីទន់ល់នឹងធ្វើស្រែកាប់ចំការ
ដូចមនុស្សនោះទ្បើយ រូបខ្ញុំនេះគាប់ចិត្តខ្ញុំហើយ ព្រះអង្គមិន
បាច់តែទៀតទេ ឯការដែលទាស់នោះ យើញទាស់តែសត្វឱដ្ឋ
គឺរូបជាសេះ តែកវាទៀងដូចជាកកុកយើញមិនសំណាំសមជាសត្វ
ពាហនះទ្បើយ"។

ព្រះឥសូរក៏ត្រាស់ទៅឱដ្ឋវិញថា "ម្ដេចចៅឱដ្ឋរូបកាយចៅ

ឯងសព្វថ្ងៃនេះស្រួលបួលហើយឬៗនៅទាស់ត្រង់ណាខ្លះ ចូរថាទៅមើល យើងនឹងកែឲ្យ?។

សត្វឱដ្ឋក៏ឆ្លើយថា "ព្រះអង្គសាងរូបកាយខ្ញុំមានកទៃឯង អាចអើតស៊ីស្លឹកឈើខ្ចីៗបាន ហើយមានកំលាំងខ្លាំងក្នុងការបន្ទុកអាស្រ័យស្មៅផឹកទឹកឆ្អែតហើយ អាចអត់បាន៧ ថ្ងៃមិនតោងអាស្រ័យក៏បានហេតុនេះ ខ្ញុំយល់ថា ព្រះអង្គសាងរូបកាយខ្ញុំនេះវិសេសណាស់ហើយ មិនចាំតែប្រែទៀតទេ សូមព្រះអង្គកែរូបត្រីអនន្តមច្ឆាវិញ ព្រោះត្រីនោះរូបធំណាស់មិនសមនឹងភាពជាជាតិមច្ឆាទៀយ"។

ព្រះឥសូរក៏សួរត្រីវិញ "ត្រីឆ្លើយថាព្រះអង្គសាងរូបខ្ញុំ មានកាយដ៏ធំលើសគេ អាចហែលហក់ក្នុងមហាសាគរសមុទ្រធំ ឥតក្តីកោតក្រែងនឹងនរលកខ្យល់ព្យុះ នេះជាការស្រួលហើយ មិនចាំកែទៀតទេទាស់តែសត្វស្រមោច ព្រះអង្គសាងរូបតូចណាស់ទាបណាស់ គេដើរជាន់ពីលើបាន សូមព្រះអង្គកែវាទៀតចុះ"។

ព្រះឥសូរក៏សួរទៅស្រមោច ដោយការក្រែងមិនគាប់ចិត្ត ឯស្រមោចក៏ឆ្លើយថា "ព្រះអង្គសាងរូបខ្ញុំតូចនេះស្រួលពេកហើយ តែមានភ័យអន្តរាយមកដល់កាលណា ចង់រត់ជ្រកក្នុង



សម្រាមឬកាកអំពៅក៏ឥតទើស ឯខាងអាហារសោតក៏រកបានងាយតែបាយ ឬអង្ករ១ គ្រាប់ក៏ទទួលទានបានឆ្អែតបរិបូណ៌រូបកាយខ្ញុំនេះ ឃើញស្រួលលើសសត្វនានាក្នុងលោកនេះ មិនតោងចាំកែជាថ្មីទៀតទេ"។

ព្រះឥសូរ ឮសត្វប្រាប់ក្តីសុខចិត្តគ្រប់គ្នាដូច្នោះក៏ស្ងៀមនៅហោង។

និទានទៀងនេះ បានជាគតិយ៉ាងណាចូរឯងអត្ថាធិប្បាយទៅមើល?។

កូនសិស្សតបថា និទាននេះបានគតិដូចពាក្យសុភាសិតគឺចប្បាប់ចាស់ថា "ពាក្យចាស់ពាក្យពីព្រេងទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ មើលទៅយល់ប៉ុនទាំងភ្នំ"។

មួយទៀត មានគតិក្នុងលោកនីតិថា

តិលមត្តំ បវេស្សវ
អប្បទោសញ្ច បស្សតិ
ជាឍ្យិកេរំបិ សទោសំ
ខលជាតោ ន បស្សតិ

បុគ្គលយល់ទោសអ្នកដទៃ តូចប៉ុនគ្រាប់ស្វែឬល្ហសតទោសខ្លួនប៉ុនដូងទាំងសំបក បែរទកទិះគន់គយមិនយល់ ។

តម្រាសត្វលោកទាំងអស់សឹងឃើញតែទោសគេត្រង់ទោសខ្លួនមើលមិនយល់ ដូចកលសត្វទាំងឡាយមានពានរជាដើម ដែលព្រះឥសូរសួនរូបកាយទៀងខ្លួន សឹងឃើញតែរូបអ្នកដទៃទាស់មិនត្រូវភ្នែកខ្លួនទាំងអស់ ឯត្រង់រូបកាយរបស់ខ្លួនឯង សឹងតែអួតថាល្អ ថាគាប់ចិត្ត ឥតក្តីទាស់អ្វីទៀយ ។ អ្នកប្រាជ្ញគប្បីពិចារណាទៅទៀតចុះ ។

**ចប់តម្រាឃើញតែទោសគេទី ១២**

មានបរមខត្តិយរាជមួយព្រះអង្គ ទ្រង់ព្រះនាមមហាចក្រាមហិសរាធិបតី មានឫទ្ធានុភាពផ្សាយអាណាចក្រទូទៅទាំងសាកល ។

មានស្តេច១០១ នាំសួយសារដង្ហាមាសចូលមកថ្វាយ ទោះស្តេចគ្រឿង នាគ យក្ខ ទេវតានឹងសត្វ សីហរាជ ព្យគ្ឃរាជ តោ លៀងភា មហិសា ក៏សឹងចុះចូលមូលមកថ្វាយបង្គំ សុំជាផ្លូវព្រះរាជមេត្រីទាំងអស់ ។ គ្រាកាលនោះមានស្តេចស្រមោចខ្មៅ១ ចង់ទៀងទៅសុំថ្វាយផ្លូវព្រះរាជមេត្រី នឹងស្តេចនោះដែរ ។



ថ្ងៃមួយទើបស្តេចស្រមោចនាំពួកបរិវារអាត្មា ទៅកាន់ផ្ទះសេនាបតី ដល់ហើយក៏និយាយថា "អ្នកសេនាបតីខ្ញុំនេះ មានចិត្តស្រទ្បាញ់ព្រះកន្ទុណាជាម្ចាស់អ្នកឯងនេះណាស់ ខ្ញុំមកនេះដើម្បីថ្វាយខ្លួនសុំព្រះអង្គជាផ្លូវទៅព្រះរាជមេត្រីផង ដូច្នេះអ្នកសេនាចូរមេត្តានាំប្រព្រឹត្តហេតុរបស់ខ្ញុំនេះ ចូលទៅក្រាបបង្គំទូលទ្រង់ជ្រាបជាមុន ព្រះអធ្យាស្រ័យតែជាទ្រង់ប្រោសព្រមឬពុំព្រម ដ្បិតខ្ញុំជាជាតិសត្វតូចទាប តែក្រែងព្រះទ័យយល់ថាពុំសមគួរ" ។

ឯអគ្គមហាសេនាបតី បានស្តាប់ពាក្យស្រមោចដូច្នោះក៏ទទួលពាក្យទើបទៀបអាត្មាម្ជុំម្នាចូលទៅគាល់ព្រះបរមខត្តិយា ក្រាបទូលតាមពាក្យស្តេចស្រមោចនោះគ្រប់ប្រការ ឯព្រមហិសរាជ្ញថាស្រមោចចង់ចូលមកជាព្រះរាជមេត្រី នឹងព្រះអង្គដូច្នោះក៏ទ្រង់ខាត់ព្រះទ័យ ដោយសេចក្តីយល់ថា សត្វស្រមោចសង្ហារជាសត្វថោកទាប មិនគួរនឹងរាប់អានទៅទទួលមេត្រីនឹងវា ឲ្យអាបព្រះកិត្តិយសព្រះអង្គគិតហើយទើបត្រាស់ថា "អាសត្វស្រមោចជាតិតូចទាបណាស់ យើងជាស្តេចធំពុំគួរនឹងទៅតាំងផ្លូវព្រះរាជមេត្រីនឹងវាទៀយ អ្នកឯងទៅប្រាប់វាចុះថាយើងមិន

ទទួលមេត្រីទេ យើងមេត្រីតែនឹងសត្វធំៗយ៉ាងរាជសីហ៍ជាដើម"។

ឯអគ្គមហាសេនាបតី ជាអ្នកមានបញ្ញាជ្រៅទើបក្រាបទូលទៅថា "ធម្មតានាយជាងឈើឬជាងទងសឹងមានគ្រឿងដែកតូចធំសម្រាប់ធ្វើការការឯណាធំត្រូវប្រើគ្រឿងធំ យ៉ាងដែកធាបពន្លាកធំទៅ ការឯណាតូចល្អិតត្រូវប្រើគ្រឿងតូចៗទៅ ដូចយ៉ាងការរាជការរបស់ល្អងធូលីព្រះបាទសព្វថ្ងៃនេះ រាជការឯណាធំ ក៏ត្រូវប្រើយកឬគ្រុឌឬរាជសីហ៍ជាដើមទៅបើរាជការឯណាតូចល្អិតដល់មក យើងត្រូវប្រើសត្វតូចៗ ទៅតាមការនោះដូចយ៉ាងសត្វស្រមោចក៏មានប្រយោជន៍ខ្លះដែរ មានរឿងនិទានក្នុងទសជាតកំ គឺរឿងព្រះមហោសថបណ្ឌិតពោធិសត្វថា កាលនោះព្រះបាទវិទេសរដ្ឋរាជមានកែវបុរាណ ១ ជាគ្រឿងប្រដាប់រូប កែវនោះវែងមានរន្ធវៀចជាសណ្ឋានខ្ចៅបុរាណគេចោះដាក់ខ្សែប្រើបានដល់យូរមក ខ្សែនោះចាស់ទេចវិលក៏ដាច់ចេញអំពីដួងកែវ នឹងរកអ្នកឯណាយកខ្សែដៅតដាក់ដួចមុនវិញពុំបាន ព្រះបាទវិទេសរដ្ឋរាជប្រើរាជអាមាត្យ ឲ្យនាំយកកែវនោះទៅឲ្យព្រះពោធិសត្វដាក់ខ្សែ ឯព្រះមហាសថបណ្ឌិតមានបញ្ញាអាចដៅតកែវនោះ គឺលោកយកខ្សែសូត្រមកវៀរត្រាញ់ ហើយយកស្ករលាយលាបចុងខ្សែក្នុងរន្ធកែវនោះ លាបទឹកឃ្មុំដាក់ជានុយស្រមោច ឯស្រមោចទាំងឡាយកាលធុំក្លិនស្ករទឹកឃ្មុំហើយក៏នាំគ្នាចូលទៅក្នុងរន្ធកែវ ស៊ីស្ករទឹកឃ្មុំខាំទាញចុងខ្សែទៅតាមរន្ធវៀចចេញទៅម្ខាងបាន ទើបមហាសថបណ្ឌិតទាញខ្សែដៅតកែវបុរាននោះបាន ហើយឲ្យនាំទៅថ្វាយព្រះបរមក្សត្រិយ៍ក្នុងព្រះរាជបុរីវិញ។ រឿងបុរាណមានមកយ៉ាងនេះ ហេតុដូច្នេះសូមព្រះអង្គទ្រង់ទទួលផ្លូវព្រះរាជមេត្រីនឹងស្តេចស្រមោចនោះផងចុះ"។



ឯព្រះបាទមហិសរាធិបតី បានស្តាប់ពាក្យសេនាបតីទូលនាំរឿងបុរាណ ជាគតិដូច្នោះស្តេចក៏ព្រម ទើបត្រាស់ថា "អើអ្នកសេនាបតី បើដូច្នោះអ្នកទៅប្រាប់ស្តេចស្រមោចនោះផងចុះថាយើងទទួលមេត្រីហើយ ឲ្យទាំទីលទៅទីស្ថានទាំចុះ មិនចាំទៀងមកគាល់យើងទេ បើយើងមានរាជភារត្រូវទៅការក សឹមឲ្យទៀងមកគាល់"។

ឯលោកអគ្គមហាសេនាបតី ក៏ក្រាបថ្វាយបង្គំលាចេញចាកទីគាល់ ទៅថ្លែងសេចក្តីនោះប្រាប់ស្តេចស្រមោចៗក៏មានចិត្ត

ត្រេកអរដោយសមត្ថិប្រាថ្នាទើបលាសេនាបតីនាំពួកពលទៅ
កាន់លំនៅនៃអាត្មាទីញ្ញហោង។

លុះនៅមកមានកាលសម័យថ្ងៃមួយ ព្រះបាទមហិសរាធិបតី
ស្តេចផ្ទំលើព្រះទែនទី មានសត្វក្តីស១ ទាវចូលទៅក្នុងវន្ទព្រះ
ភាណ៌នៃព្រះអង្គ ស្តេចក៏ទ្រង់ក្រោកចាកទីបន្ទំ ខំយកចង្កៀល
ឆ្កៀលចាក់យកក៏ពុំបាន ទាវីតតែនុកទៅខាងក្នុងស្តេចក៏ទឹងឈឺ
ពន់ពេកណាស់ ដាស់សម្តេចព្រះទេវី ន្ងូវស្ត្រីព្រះស្នំក្រមការឲ្យ
ជួយយកក្តីសនោះ។

ឯអស់ស្ត្រីស្នំទាំងឡាយ មាននាងទេវីជាប្រធានលឹងភីតភ័យ
ទីទែៗ នាំគ្នាហៅពេទ្យហ្មមកប្រកបឱសថដាក់ចាក់ទៅ ក្តីស
នោះក៏មិនចេញទៅឡើយ ព្រះបរមខត្តិយរាជក៏ទឹងទីតតែឈឺខ្លាំង
តាំងពីមជ្ឈិមយាមយប់ត្រាដល់បច្ចូសសម័យ ស្តេចក៏នឹកទៅដល់
ត្រុងុ នាគយក្ខ គន្ធព្វ កុម្ភណ្ឌ រាជសីហ៍ នរសីហ៍ ឲ្យមកជួយព្រះ
អង្គ។

ឯអស់ស្តេចទាំងឡាយមានស្តេចត្រុងុជាដើមក៏មកកាន់ទីប្រជុំ
ជំនុំគ្នា ដើម្បីនឹងគិតយកក្តីសនោះជាកោលាហល លឹងទញ្ញៀទាល់
តម្រិះប្រាជ្ញាទីទែៗ ពុំមានអ្នកឯណាមួយនឹងអាចយកអាសាបាន។



គ្រាកាលនោះ សេនាបតីនឹកទៅដល់ស្តេចស្រមោចៗ ក៏នាំពួក
ពលបទាវរាត្មាមកកាន់ទីប្រជុំ ទើបសេនាបតីប្រាប់ថា "ព្រះ
កន្ទុណាជាម្ចាស់យើងមានទុក្ខ ដោយសត្វតូច ចូលទៅក្នុងព្រះកា
ណ៌នៃព្រះអង្គ អស់ពួកស្តេចនានាលឹងទញ្ញៀទាល់ប្រាជ្ញាទីទែៗ
សេចក្តីនេះតើអ្នកឯងគិតកែយ៉ាងណាបាន យើងរាល់គ្នាអស់
តម្រិះប្រាជ្ញាហើយ"។ ស្តេចស្រមោចបានស្តាប់ដូច្នោះហើយក៏
ទទួលយកអាសា ទើបប្រើស្រមោចខ្មៅពីរជាសេនាទាហាន
ឲ្យចូលទៅក្នុងព្រះកាណ៌នៃព្រះមហិសរាធិបតី ឯស្រមោចទាំង
ពីរ ក៏នាំគ្នាចូលទៅខាំទាញ្ញយកក្តីសអំពីខាងក្នុងព្រះកាណ៌
ចេញមកខាងក្រៅបានហើយបង្ហាញដល់ប្រជុំជន មានព្រះបាន
មហិសរាធិបតីជាដើម ឯបណ្តាប្រជុំជនទាំងឡាយ លឹងមានចិត្ត
ត្រេកអរសាទរមហិមា នាំគ្នាសរសើរក្តីគាប់របស់ស្តេចស្រមោ
ចនោះ ជាអនេកបរិយាយផ្សេងៗ ហើយនាំគ្នាថ្វាយបង្គំលា
ចេញទៅកាន់លំនៅនៃខ្លួនទីទែៗ។

ទៀងនេះ បានគតិដូចបុគ្គលអ្នកនាប់អានតែអ្នកមានយស
សិទ្ធន្ងូវអ្នកមានសម្បត្តិ ត្រង់អ្នកតូចពូជទាបឬញ្ញាតិសន្តានជា
អ្នកក្រីក្រ ពុំនាប់អានទៀយ លុះដល់ខ្លួនមានកិច្ចការ ដូចមានអា

ទាហមង្គលជាដើមដល់មកនឹងទៅពីងរកអ្នកមានសម្បត្តិ មានយសសក្តិនោះមកឲ្យជួយនែកសែង ដងទឹក បុកស្រូវ ពុះខ្សែឯណាក៏បាន តោងពឹងអ្នកតូចតាមការទាប ការគួរធ្វើបាននោះឯង ដូចស្តេចមហិសរាធិបតី បើមិនទទួលមេត្រីនឹងស្តេចស្រមោចនោះហើយ ដល់ក្តីសទៅចូលត្រចៀក ធ្វើម្តេចនឹងយកក្តីសនោះចេញពីក្នុងត្រចៀកបាន ទៅប្រើស្តេចគ្រុឌ នាគ យក្ខ គន្ធព្វ កុម្ភណ្ឌ រាជសីហ៍នោះឯណា នឹងចូលក្នុងត្រចៀកបាន។ បទនេះអ្នកប្រាជ្ញគួរពិចារណាមើលជាគតិលោកហោង។

**ចប់តម្រាពីងតូចរួចទុក្ខភ័យទី ១៣**

មានសត្វស្មាន់១ ក្អែក១ អណ្តើក១ យកគ្នាជាសម្លាញ់តែងពឹងពាក់គ្នាទៅនិញទៅមក។ ថ្ងៃ១ ស្មាន់ទៅរកស៊ីនៅព្រៃ១ ក៏ជាប់អន្ទាក់ព្រានព្រៃ ក្អែកនឹងអណ្តើតនាំគ្នាដើរកស្មាន់នោះលុះទៅដល់ដាយព្រៃក៏ស្រាប់តែឃើញស្មាន់ជាប់អន្ទាក់ ទើបចូលទៅសួរថា "សម្លាញ់ឯង ហេតុអ្វីដើរកស៊ីមិនមើលអន្ទាយ មកឲ្យជាប់បន្ទាក់គេយ៉ាងនេះ"។ ស្មាន់ក៏ឆ្លើយថា "ខឹសម្លាញ់អើយ អញនេះបានជាខុសហើយចូរសម្លាញ់គិតកែខៃជួយអាយុអញផងចុះ"។



ឯក្អែកនឹងអណ្តើកក៏ទទួលជួយដោះទុក្ខភ្សើនក្អែកហើរទៅពាំនាំទឹក មកស្រោចខ្យែអន្ទាក់ឲ្យទន់ឯអណ្តើកក៏ខាំខ្សែអន្ទាក់នោះឯង ក្អែកនឹងអណ្តើកព្យាយាមខាំកាត់អន្ទាក់នោះតាំងតែពីបឋមយាម ដរាបដល់បច្ចិមយាម ទៀបនឹងភ្លឺស្វាងកាត់ដាច់បានពីរធ្នូងនៅសល់មួយធ្នូង ក៏ជួនពេលព្រានព្រៃមក ទើបក្អែកនឹងអណ្តើកស្មើនសតិស្មាន់ថា "សម្លាញ់អើយពេលនេះម្ចាស់អន្ទាក់មកជិតដល់ហើយ យើងជួយកាត់បានតែពីរធ្នូងនៅសល់មួយធ្នូងចូរសម្លាញ់ខំបោលកន្ត្រាក់ដោយខ្លួនឯងឲ្យដាច់ចុះ"។ កាលសត្វទាំង៣ កំពុងនិយាយគ្នាដូច្នោះ នាយព្រានព្រៃក៏មកដល់ ទើបក្អែកនឹងអណ្តើកក៏ចេញចាកទីនោះចូលទៅពួនក្នុងព្រៃនៅខាង ចាំមើលដំណើរស្មាន់នោះឯង ឯស្មាន់សោតកាលបើនាយព្រានមកដល់ខ្លួនក៏សុះកន្ត្រាក់ផ្តាច់អន្ទាក់នោះដាច់បានហើយបោលចូលព្រៃទៅហោង។

ឯនាយព្រាននឹកស្តាយស្មាន់ណាស់ ក៏រត់ដេញស្មាន់នោះតែតាមពុំទាន់ ទៅប្រទះលើអណ្តើកដែលពួននោះ ទើបនាយព្រានចាប់អណ្តើកនោះហើយក៏ទិលមកធ្វើអន្ទាក់នោះទៀត។

ឯក្អែកឃើញនាយព្រានចាប់អណ្តើកបានដូច្នោះក៏និយាយនឹង

ស្មាន់ថា ចូរអ្នកកែ្លងធ្វើជាបាក់ជើងដើរទៅខាងមុខនាយព្រាន
ដេញ នាយព្រានគង់នឹងដាក់អណ្តើកចោលនៅកណ្តាលទាលទត់
ដេញអ្នកឯងមិនលែង ហើយអ្នកឯងនឹងរត់គេចមកក្រោយទៀ
ខាំពាំអណ្តើកនោះបោលចូលព្រៃទៅ ឲ្យរួចពីដៃអាព្រានព្រៃ
នោះ។

ឯស្មាន់ក៏ធ្វើតាមពាក្យក្អែកបង្គាប់នោះឯង លុះស្មាន់បោលទៅ
ជិតនាយព្រានហើយ ក៏ធ្វើអាការជាសត្វបាក់ជើងម្ខាង បោល
បោះតែជើង៣ ចំពោះមុខព្រានព្រៃនោះឯង ឯនាយព្រានពុំ
ដឹងអាការសត្វក៏សំគាល់ថា ស្មាន់នេះ ត្រូវវិអន្ទាក់ទាំខំកន្ត្រាក់ទាល់
តែជាច់បាន ទំនងជាទាបាក់ជើងនេះ ព្រោះខ្វែរអន្ទាក់អញ្ចឹទា
ទាត់ត្រូវនោះឯង គិតហើយនាយព្រាន ក៏ដេញទៅដើមប្លឹនឯង
ប្រហារ។

ឯស្មាន់បែរមក ឃើញនាយព្រានមិនទាន់ដាក់អណ្តើកចោល
ដូច្នោះក៏កែ្លងធ្វើជាពុំលឿង បោលទៅបន្តិចៗ នាយព្រានចូល
ចិត្តថាស្មាន់ពិការជើងបោលពុំលឿនដូច្នោះ ក៏គិតថា អញ
ប្រយោជន៍អ្វីនឹងអារអណ្តើក១ សាច់ទាស្តួសុីបានតែព្រឹកល្ងាច
ប៉ុណ្ណោះគួរតែចោលទាចេញចុះ នឹងខំដេញចាប់អាស្មាន់ឲ្យបាន



ដ្បិតទាជាសត្វធំសាច់ច្រើន លើសអារអណ្តើកនេះគិតហើយនាយ
ព្រានក៏ចោលអណ្តើកនោះនៅលើគុម្ពស្បៃ ហើយរត់តាមស្មាន់
នោះទៅ។ ឯស្មាន់ដឹងថានាយព្រានចោលអណ្តើកហើយ ក៏នឹង
ធ្វើកលបោលដន្លនាយព្រាន ឲ្យដេញចេញទៅផុតព្រៃស្បៃទៀ
បានឱកាសហើយ ស្មាន់ក៏បោលគេចមកក្រោយបានទៅដល់
អណ្តើកហើយ ក៏ពាំអណ្តើកនោះបោលបោះផ្លោះចូលទៅក្នុង
ព្រៃធំ។ ឯក្អែកក៏ហើរនាំផ្លូវទៅដរាបដល់ព្រៃ១ ជាព្រៃផុត
មនុស្សដើរទៅដល់សត្វទាំង៣ ក៏នាំគ្នាអាស្រ័យនៅក្នុងព្រៃ
នោះជាសុខសប្បាយហោ។

ទើរឯនិទាននេះ ឯងយល់ចុះក្នុងគតិយ៉ាងណាចូរថាទៅមើល។
កូនសិស្សក៏តបថា ទើរឯនេះចុះគតិកសា្តណមិត្រល្អបុគ្គល
ឯណាបានមិត្រល្អ យ៉ាងក្អែកនឹងអណ្តើកដែលជួយដោះស្មាន់ជា
មិត្រឲ្យរួចចាកទុក្ខបានបុគ្គលនោះហៅថាមានមិត្រល្អ គួរគប្បី
សេគប់ ក៏ឯមិត្រនេះលោកសំដែងថា កុលបុត្រគប្បីបំទុង
ដោយស្មាន៥ ប្រការ គឺបែងចែកវត្ថុឲ្យ១ និយាយចរចាពាក្យ
ពីរោះ១ ប្រព្រឹត្តប្រយោជន៍១ ភាវនជាអ្នកមានធុរៈប្តូនស្មើ
ជាប្រក្រតី១ មិនកែ្លងពោលពាក្យឲ្យឃ្លៀងឃ្លាតចាកភ្តីត១។

មិត្របានទទួលបំនុងដូច្នេះហើយត្រូវអនុគ្រោះកុលបុត្រនោះ
ដោយស្ថាន៥ ប្រការទីញ្ញ គឺឃើញមិត្រនោះ ដល់នូវទីក្តីលំបាក
នាទីស្ថានឯណាមួយហើយស៊ូនៅរកប្រាមិត្រ ពុំគិតលះចោលយ៉ាង
នេះប្រការ១ ជួយរកប្រាទ្រព្យសម្បត្តិរបស់មិត្រ ដែលមិត្រលុះ
ក្តីប្រមាទ១ កាលបើមានភ័យ ទទួលជាទីពឹងពុំនាក់បាន១ មិនលះ
ចោលមិត្រក្នុងកាលវិបត្តិ មានកាលស្រូវទំថ្លៃជាដើម១ រាប់អាន
រហូតដល់ទំងញ្ញាតិរបស់មិត្រ១ ត្រូវទំជាស្ថាន៥ ប្រការហោង។
បុគ្គលក្នុងលោក គប្បីរកមិត្រមានធម៌អនុគ្រោះ៥ ប្រការដូច
សំដែងមកនេះ ទើបបានក្តីសួស្តីមង្គល ចំរើនក្តីសុខសម្រាន្តដូច
សត្វទាំង៣ នោះហោង។

**ចប់តម្រាគតិសុភមិត្រ។**

មានសត្វស្មាន់១ ក្អែក១ ជាសម្លាញ់គ្នានៅឃ្លែមក មានចចក១
ដើរទៅជួបនឹងស្មាន់ ចូលទៅនិយាយមេត្រីក្តីស្នេហានឹងស្មាន់
នោះ ស្មាន់សោតក៍លុះក្តីស្រឡាញ់ចចកយ៉ាងស្និទ្ធ សត្វទាំងពីរ
តែងទៅមករកគ្នាជាញឹកញយ។

ឯក្អែកជាសត្វមានប្រាជ្ញា ស្គាល់អាការកិរិយានៃចចកនោះជា
សត្វកោងឥតក្តីសុចរិត ទើបនិយាយហាមស្មាន់ថា "អ្នកឯងកុំទៅ



ចូលចិត្តស្រឡាញ់អាចចកនោះទៀយ អាចចកនោះមិនស្លូត
ត្រង់តមិត្រឯងទេ វាជាសត្វប្រចុបប្រចែង ក្តែងធ្វើជាមិត្រ
ស្និទ្ធស្នាលនឹងអ្នកឯង ធ្វើឲ្យអ្នកលុះលង់ដោយកលវាៗ នឹងយាយី
អ្នកឯងវិញ្ញពុំខាន"។ ឯស្មាន់នោះលុះអំណោចកលចចកមកយូរ
ហើយ លុះឮក្អែកជាមិត្រពោលហាមក៍ពុំតាមពាក្យក្អែកនោះ
ទៀយ ឯចចកក៍ចេះតែបបួលស្មាន់ទៅលេងនឹងទីខ្លួនទៀយៗ
ថ្ងៃមួយចចកបានឃើញអន្ទាក់ព្រានព្រៃតាំងនៅដោយព្រៃ១
ទើបកើតក្តីទ្រុស្តមិត្រគិតថាចាំអញទៅបបួលស្មាន់ ឲ្យវាមក
រកស៊ីនៅទីនេះនឹងបញ្ចោតវា ឲ្យជាប់អន្ទាក់ព្រានព្រៃនេះ
ដល់វាស្លាប់អញនឹងស៊ីវាហោង។ ចចកគិតដូច្នោះ ក៏ទៅកាន់
សំណាក់នៃស្មាន់ ដល់ហើយទើបនិយាយបបួលថា "សម្លាញ់អើយ
មកយើងនឹងទៅរកស៊ីនៅទីដាយព្រៃខាងនោះ ព្រៃនោះខ្ញុំ
ផ្លាប់ទៅរកអាហារបរិភោគងាយណាស់ ឯខាងស្មៅឬស្លឹកឈើ
ជាចំណីមិត្រឯងសោត ក៍មានបរិបូណ៌តាមចិត្តនឹងបរិភោគ"។

ឯស្មាន់បានឮចចកបបួលដូច្នោះ ក៍ទៅតាមចចក។ ក៍នាំស្មាន់
ទៅត្រង់ទីអន្ទាក់ព្រានព្រៃនោះឯង ស្មាន់សោត ឆោតមិនដឹង
កលមិត្រ គឺតនឹងប្រទូស្តអាត្មាដើរទៅ។ ជាន់ទៅលើអន្ទាក់។

ក៍ទាតីទ្ងែជឹងក្រោយនៃស្មាន់ឃួនទ្បើង ស្មាន់ក៍ភិតភ័យតក្តមា
ស្រែកឲ្យចចកជួយ ចចកក៍ធ្វើកិរិយាដូចជាភ្ញាក់ផ្អើលនឹង
មនុស្សមកដល់ខ្លួន សុះនត់ទៅពួននៅក្នុងព្រៃស៊ុមទ្រុមសម្ងំចាំ
មើលស្មាន់នោះ នឹងបម្រះនឡៀលកន្ត្រាងទៅយ៉ាងណា បើ
ស្មាន់អស់កម្លាំងដួលចុះកាលណា នឹងចេញមកស៊ីស្មាន់នោះឯង។
ថ្លែងពីក្អែក កាលបើពុំឃើញស្មាន់នៅទីប្រក្រតីក៍ហើរទក
ស្មាន់នោះ តាមដងព្រីកៗព្រៃដរាបទៅដល់ទីជាយព្រៃ ក៍បាន
ឃើញស្មាន់ជាប់អន្ទាក់ព្រានព្រៃទើបហើរចុះទៅទំលើមែ
ឈើ ហើយនិយាយទៅថា "ះហែសម្លាញ់អើយ! ហេតុអ្វីក៍បានជា
មកប្រមាទការឲ្យជាប់អន្ទាក់មនុស្សយ៉ាងនេះ"។
ស្មាន់តបថា "ការអស់នេះគឺខ្លួនខ្ញុំឯងខុសពិតហើយ ព្រោះ
អាចចកវាបញ្ជោតឲ្យមករកស៊ីនៅទីនេះវានាំឲ្យឯងជាប់អន្ទា
ក់គេ ត្រង់ខ្លួនវាគេចរត់បាត់ពីទីនេះទៅ មិនដឹងជាវាទៅឯណា
អើសំឡាញ់ចូរអាណិតដោះខ្ញុំឲ្យរួចពីអន្ទាក់នេះមុនចុះ"។
ឯក្អែកក៍ប្រាប់ឆ្កាយស្មាន់ថា "បើនាយព្រាណមកដល់កាល
ណា ចូលអ្នកឯងក្តែងធ្វើជាស្លាប់ តាំងរូបឲ្យទឹងប្រឹងអត់ដង្ហើម
ធ្វើឲ្យនាយព្រានទុកចិត្តថាស្លាប់មែន បើនាយព្រានដោះអ្នក



ឯងកាលណា អ្នកចាំពាក្យខ្ញុំថាខ្វក បើឮពាក្យខ្ញុំថាខ្វកកាលណា
ចូរអ្នកឯងខំសុះបោលបោះផ្លោះរត់ចូលព្រៃទៅ ឲ្យផុតអំពី
ដៃមនុស្សហោង" ឯស្មាន់ក៍ទទួលពាក្យបង្គាប់នៃក្អែកសព្វគ្រប់
ប្រការ។
លុះដល់ពេលនាយព្រានព្រៃទៀបខ្លួនហើយយាត្រាទៅមើល
អន្ទាក់ ស្រាប់តែឃើញស្មាន់ដេកស្លាប់ក៍ចូលចិត្តថាស្មាន់ដេក
ស្លាប់ឃួនហើយ ទើបប្រមាទដោះស្មាន់ចាកអន្ទាក់ដាក់ម្នាង
ហើយឈរទ្បើងមើលឆ្វេងមើលស្តាំ។ ឯក្អែកឃើញនាយព្រាន
ប្រមាទហើយ ក៍ស្រែកខ្វកជាសញ្ញាទ្បើងមួយរំពេច ស្មាន់ក៍សុះ
ទ្បើងបោលបោះ ផ្លោះរត់ចូលព្រៃទៅជាមួយនឹងក្អែកជាអ្នក
នាំផ្លូវ ឯនាយព្រានព្រៃឃើញស្មាន់រស់បោលផ្លោះដូច្នោះក៍សុះ
ចាប់លំពែងរត់ដេញដល់ទីមួយក៍ពួយលំពែងទៅត្រង់ព្រៃស៊ុម
ទ្រុម លំពែងនោះក៍ធ្លាក់ទៅត្រូវគល់កនៃចចក ដល់ទូវិត្តិមរណ
កាលក្នុងព្រៃស៊ុមទ្រុមនោះឯង។
ឯក្អែកក៍ហើរនាំស្មាន់ទៅកាន់លំនៅ ផុតអន្តរាយនឹងព្រាន
យ៉ាយហោង។
ទ្បើងនិទាននេះ បានគតិយ៉ាងណាឲ្យថាទៅមើល?។

កូនសិស្សតបថា ចចកទ្រុស្តមិត្របង់ជីវិតខ្លួនឯងបានតតិធម៌ថា បុគ្គលសុចរិតក្តីប្រទូសរាយតបមនុស្សឯណាមួយហើយៗ មនុស្សនោះទៅប្រទូសរាយតតែឥតទោសនឹងខ្លួន យ៉ាងដូចសត្វចចកទៅប្រទូសរាយតស្មាន់ជាមិត្រឥតទោស យ៉ាងនេះលោកថាក្តីទុក្ខទោសវិបត្តិអពមង្គល នឹងធ្លាក់ដល់មនុស្សនោះឯង ដូចចចកត្រូវលំពែងព្រានព្រៃនោះហោង។

**ចប់តម្រាជនទ្រុស្តមិត្រទី ១៥។**

មានស្តេចព្រាប១ នាំបរិវារទៅរកស៊ីនៅទីវាលស្រែបានឃើញលប់ ដែលនាយព្រានដាក់ហើយបាចសាចស្រូវអង្ករជានុ្យ ពួកព្រាបជាបរិវារទាំងឡាយឃើញនុ្យដូច្នោះ គិតនាំគ្នានឹងចុះស៊ី។

ឯស្តេចព្រាបគិតថាស្រូវអង្ករនេះ ជារបស់រកបានដោយក្រចុះហេតុម្តេច ក៏មនុស្សយកមកបាចសាចចោលរាយពាសដូច្នោះ ទំនងជានុ្យបញ្ឆោតឲ្យពួកព្រាបចុះស៊ី ហើយគេនឹងវាត់ចាប់ដោយលប់នេះឯងជាប្រាកដ ស្តេចព្រាបគិតដូច្នោះហើយ ទើបពោលហាមព្រាបជាបរិវារ មិនឲ្យចុះស៊ីស្រូវនោះទៀយ។



ឯព្រាបជាបរិវារទាំងឡាយពុំស្តាប់ទើបនិយាយគ្នាថា "យើងស្វែងរកអាហារសព្វថ្ងៃនេះ បានដោយកម្រ ឥទ្ធ្យនេះមកបានឃើញអាហារល្មមបរិភោគហើយៗ នាយយើងហាមឃាត់មិនឲ្យចុះស៊ីយ៉ាងនេះតើនឹងចាំទៅរកឯណាទៀតឲ្យលំបាក"។

ស្តេចព្រាបឮដូច្នោះក៏ថា "អ្នកទាំងឡាយគ្មានប្រាជ្ញា ឃើញតែអាហារក៏ហើរចុះស៊ី ពុំដឹងក្តីអន្តរាយទៅខាងមុខ នឹងបានទុក្ខដល់អាត្មាដូចពាក្យបុរាណថា "ព្រោះចំណីត្រូវក្តីច្រែនក្តាត់" នែអ្នកទាំងឡាយស្រូវអង្ករ ដែលគេរាយពាសទាំលនេះគឺជានុ្យដូចជាត្រីស៊ីនុ្យ ជាប់សន្ទូចគេនោះឯងហើយ ចូរអ្នកទាំងឡាយកុំចុះទៅស៊ីស្រូវគេនោះទៀយ"។

ឯព្រាបទាំងឡាយពុំជឿស្តាប់ស្តេចព្រាបហាមទៀយ នាំគ្នាចុះទៅស៊ីស្រូវ ក្នុងលប់នាយព្រានឯស្តេចព្រាបឃាត់បរិវារពុំស្តាប់ដូច្នោះ ក៏គិតថា "បើអញ្ចឹមិនចុះទៅផងមុខជាព្រាបអស់នេះនឹងវិនាសដោយដៃមនុស្សពុំខាន ល្អើយចុះអាត្មាត្រូវចុះទៅជាមួយផងចុះ" គិតហើយស្តេចព្រាបក៏ហើរចុះទៅក្នុងលប់នោះឯង។

ឯនាយព្រានឃើញព្រាបចុះច្រែនហើយ ក៏ទំលាក់ខ្សែលប់

នោះចុះមួយរំពេចព្រាបទាំងឡាយក៏ត្រូវដូចគេទៅចក្ខុងសំណាញ់នោះជាម្តង ទើបស្តេចព្រាបនិយាយថា "ម៉េចអ្នកទាំងឡាយយើញក្តីអន្តរាយជីវិតពិតហើយឬ បើដូច្នេះអ្នករាល់គ្នានឹងគិតយ៉ាងណាទើបរកជ្រាជីវិតបាន?"។

ឯព្រាបទាំងឡាយ នាំគ្នាទទួលទោសខ្លួនហើយថា "យើងខ្ញុំទាំងឡាយពុំដឹងគិតយ៉ាងណាទេ ទាល់ចំណេះអស់ហើយលោកមានឧបាយយ៉ាងណាសូមមេត្តាដោះទុក្ខយើងខ្ញុំឲ្យរួចជីវិតផង"។

ឯស្តេចព្រាបថា "ភ័យម្តងនេះជាភ័យយ៉ាងធំបំផុតកម្រនឹងកែខ្លួនបាន បើដូច្នេះអ្នករាល់គ្នាកុំប្រមាទខំខ្លួរាំតាំងសតិឲ្យខ្ជាប់ចុះ អាស្រ័យការព្រមព្រៀងចិត្តគ្នា ខំតាំងកំលាំងឲ្យព្រមគ្នាចុះ យើងប្រឹងស្ទុះហើរទៅឲ្យព្រមគ្នា ដើម្បីនឹងឲ្យលប់នេះដាច់ឃ្លាតចាកទី"។

ឯព្រាបទាំងឡាយក៏ធ្វើតាម ទើបនាំគ្នាស្ទុះហើរព្រមគ្នា ឯខ្សែលប់ក៏ដាច់ចាកទី១ រំពេចព្រាបទាំងឡាយ ក៏ហើរនាំលប់នោះទៅឯទៅលើអាកាសបាន ហើយហើរទៅដល់ដំបូកមួយជាលំនៅនៃស្តេចកណ្តុរដែលជាសំឡាញ់នឹងស្តេចព្រាបអំពីដើមមក។ ថ្ងៃដែលព្រាបទាំងឡាយទៅធ្លាក់លើដំបូកនោះ ស្តេច



កណ្តុរបានដឹងថាស្តេចព្រាបព្រមទាំងបរិវារជាប់លប់ហើរមកធ្លាក់ដូច្នោះ ក៏នាំបរិពារនៃអាត្មាចេញពីដំបូកមកកាត់លប់នោះដាច់ដាច នាំយកព្រាបទាំងនោះចេញអំពីលប់នោះបាន ឯស្តេចព្រាបព្រមទាំងបរិវារ ក៏បានរួចចេញចាកលប់ហើយប្រារព្ធប្រស្រ័យចរចាប្រាប់សេចក្តីសុខទុក្ខគ្នា ទាំងពីរដើមដល់ចប់គ្រប់ប្រការ ស្តេចព្រាបក៏សរសើរគុណនៃស្តេចកណ្តុរជាកល្យាណមិត្រផ្សេងៗហើយក៏លាគ្នាទៅកាន់លំនៅទីទៃៗហោង។

ទៀងនីទាននេះ បានគតិយ៉ាងណាចូរសំដែងទៅមើល?។

កូនសិស្សតបថា ទៀងស្តេចព្រាបនោះបានគតិគឺនាយល្អនាយប្រពៃ បុគ្គលអ្នកស្វែងរកនាយចៅហ្វាយឲ្យបានក្តីសុខនោះគប្បីស្វែងរកនាយចៅហ្វាយដែលប្រកបដោយសតិបញ្ញាអាចជួយដោះបាទឲ្យរួចចាកក្តីទុក្ខទោសបាន ដូចយ៉ាងស្តេចព្រាបដែលឃាត់ពួកបរិវារពុំបាន ហើយដឹងថាអន្តរាយចំពោះជានឹងមានដល់ពួកព្រាបជាបរិវារប្រាកដហើយ ពុំគិតលះបង់ចោលបរិវារទៀយ ស៊ូនប្រថុយអាត្មាចូលក្នុងលប់នាយព្រានជាមួយគ្នា ហើយដាស់តឿនបរិវារឲ្យប្រឹងស្ទុះហើរផ្តាច់លប់

ដោយព្រមព្រៀងចិត្តគ្នា បានទួចផុតក្តីភ័យអន្តរាយនោះបាន ។

មួយទៀតឯលប់រូបសំណាញ់គឺមនុស្សធ្វើដោយធ្មៃដាទម្ងន់ សត្វព្រាបអត្តភាពតូចកំលាំងតិចអាចផ្តាច់នាំហើរយកទៅបាន ទាំងនេះក៏ព្រោះក្តីសាមគ្គីព្រមចិត្តគ្នា តាំងព្យាយាមដោយកំលាំងស្មើគ្នាវត្តុធំពិត តែបើកំលាំងឬព្យាយាមស្មើគ្នាហើយ វត្តុធំនោះអាចនាំទៅបាន គតិនេះដូចបទបាលីមានក្នុងគម្ពីរលោកនីតិថា

ពហូនំ អប្បសារានំ
សាមក្កិយា ឧយាឧយេ
តិណេន យោត្តំ វត្តេកេ
តេន នាគោបិ ពន្ធតិ។

ជនប្រាសចាកគុណគប់គ្នាច្រើន តែចំរើនដោយក្តីសាមគ្គី អាចផ្ចាញ់បាននូវពួកនៃពៃរី ដោយវិធីសាមគ្គីដ៏ហាវហាន ។ ខ្ញុំពួនគឺជនទៀញដោយស្មៅនាំយកទៅចងពន្ធដីវិបាន រូបតូចពិតតែចិត្តស្មោះស្មើប្រាណ គង់ផ្ចាញ់បានរូបធំរលំអីយ ។

មួយទៀតបុគ្គលអ្នកស្វែងរកនាយចៅហ្វាយល្អនោះត្រូវទើសនាយល្អប្រកបដោយសង្គហធម៌៥ ប្រការគឺចាត់ការងារឲ្យបាទធ្វើតាមសមគួរដល់កំលាំង១ ឲ្យអាហារនិងទង្វាន់ដល់បាទ



១ ដួយរកព្យាបាលក្នុងទៀលបាទឈឺចាប់១ បែងចែកនបស់មានរសប្លែកឲ្យបាទបានបរិភោគផង១ លើកលែងការងារក្នុងសម័យកាល គឺបើកបាទឲ្យទៅធ្វើបុណ្យទានតាមចិត្ត១ ។

នាយប្រកបដោយសង្គហធម៌៥ ប្រការនេះទើបហៅថានាយល្អនាយប្រពៃ គប្បីបាទចូលសេពគប់ ។ មួយទៀតក្នុងគម្ពីរលោកនីតិសំដែងថា៖

ន សេវ ផរុសឹ សាមឹ ន ច សេវេយ្យ មច្ចរឹ
តតោ អបត្តណ្ហោ សាមឹ នេវ និត្តហិ តំ តេតោ

នាយអាក្រក់មិនគួរសេពគប់នោះមានអធិប្បាយថា កុំសេពម្ងាស់គ្រោតគ្រោតជាតិប្រទីញ្ចនី កុំសេព ម្ងាស់កំណាញ់គឺតកាញ់ទុន កុំសេពម្ងាស់មិនលើកដំកល់គុណ កុំសេពម្ងាស់យកបុណ្យមកសង្កត់ ។

មួយទៀតលោកខំសេចក្តីថា ម្ងាស់កំណាញ់ពាញ់កំណាចលើសម្ងាស់គ្រោត ម្ងាស់ថយជាតិមិនលើកលើសកំណាញ់ ម្ងាស់ផ្ចាញ់ផ្ចាល់ដួសលើសមិនលើកទីញ ម្ងាស់៤ នេះកុំស្រឡាញ់យកជាម្ងាស់ ។

ចប់តម្រាគតិនាយល្អទី ១៦។

មានសត្វចចកទាំងឡាយក៏ច្រើនអាស្រ័យនៅលើកោះ១
កណ្តាលសាកនថ្ងៃមួយនិយាយប្រឹក្សាគ្នាថា យើងជាសត្វអាស្រ័យ
សាច់សត្វជាភក្ក្សាហារស្វែងរកអាហារបានដោយក្រ ទោះជា
បានខ្លះសោតក៏ពុំបរិបូណ៌ ហេតុដូច្នេះគ្នាយើងគួរតែទៅនិយាយ
លួងបញ្ឆោតដំរីសារធំ ឲ្យទាច្ចុះកលយើង។ នឹងបានសាច់ទា
បរិភោគបរិបូណ៌ ហ្វូងចចកគិតឃើញឱបាយដូច្នេះហើយ ទើប
នាំគ្នាហែលទឹកទៅកាន់ត្រើយស្ទឹងចូលទៅកាន់សំណាក់នៃដំរី
សារ ដល់ហើយក៏ធ្វើកិរិយាជាអ្នកកោតខ្លាច ឱនសិរសាច្ចុះគំ
នាប់គោរពដំរីហើយស្រដីថា "បពិត្រលោកជាធំដ៏ប្រសើរសូម
លោកមេត្តាប្រោសដល់ពួកយើងខ្ញុំ ដ្បិតយើងខ្ញុំទាំងឡាយសព្វ
ថ្ងៃនេះ ឥតមានទីពឹងជួយការពារក្តីអន្តរាយសោះ
ឥឡូវទៅបានប្រឹក្សាគ្នាឃើញថា ព្រះតេជព្រះគុណនេះ ជាសត្វ
ធំឱត្តមសមគួរជានាយលើយើងខ្ញុំទាំងឡាយ។ ប្រគល់កាយជា
បាវបំរើព្រះតេជព្រះគុណចាប់ដើមពីថ្ងៃនេះតទៅ" ។

ឯដំរីសារឥតប្រាជ្ញា បានឮចចកទាំងឡាយនោះមកនិយាយ
បញ្ឆោតដូច្នោះ ក៏ត្រេអរស្រុះស្រួលទទួលជានាយលើហ្វូង
ចចក ។



ឯចចកទាំងឡាយចាប់ដើមពីថ្ងៃនោះមកវានាំគ្នាគោរព
ប្រតិបត្តិបំរើដំរីដោយក្តីមាយា ថ្ងៃមួយចចកនាំគ្នាចូលទៅវន្ទា
ដំរីស្រដីបបួលថា "បពិត្រលោកជានាយ ហើយខ្ញុំទាំងឡាយអា
ស្រ័យនៅក្នុងទីព្រៃនេះពុំសប្បាយ ព្រោះរកអាហារបានដោ
យក្រ សូមទានយើងខ្ញុំ សូមអញ្ជើញលោកនាយឆ្លងទៅនៅ
ឯកោះធំ កោះនោះបរិបូណ៌យើងខ្ញុំនឹងហែហមទ្បាមលោក
នាយទៅនៅឯកោះនោះ នឹងបានជាអធិបតីលើពួកយើងខ្ញុំទាំង
ឡាយ មួយទៀតឯពួកយើងខ្ញុំដែលនៅឯកោះនោះ ក៏មាន
ច្រើនគ្នា សូមលោកនាយមេត្តាត្រាទៅជាកំពូលនៃយើងខ្ញុំ
ហោង" ។

ឯចចកនៅកោះបានឮពួកខ្លួនខាងត្រើយលួចទៀងដូច្នោះក៏
នាំគ្នាលួចឯទៀងទទួលគ្នា ហើយប្រុងប្រៀបអាត្មាទីទែ។
ដើម្បីនឹងចុះហែលទឹកទៅជួយគ្នាខាំដំរីនោះ ឲ្យលុះក្តីមរណ
កាលកណ្តាលមហានទីនោះឯង ។

ឯដំរីសារស្រាទឹងបុណ្យហែលមកដល់កណ្តាលមហាទឹ ត្រូវទឹក
ជ្រៅផុតជើងផុតដៃ នឹងអាស្រ័យថ្មែថែនដីពុំបាន ក៏អណ្តែត
ខ្លួនប្តែងប្តោង។ ឯចចកទាំងឡាយដឹងជាដំរីផុតជើងផុតដៃ

នឹងអាស្រ័យព្រៃចចាក់ពុំបានដូច្នោះ ទាក៏នាំគ្នាហែលទៅឯទំលែ
ខ្ងងហើយខាំកកេរសាច់ពោះដីនិត្រាតែផ្ទុះ ទឹកក៏ចូលទៅក្នុង
ពោះដីនោះពេញ ដីនោះដល់នូវទុក្ខមរណកាលកណ្តាលគង្គា
ពួកចចកក៏នាំគ្នាបរិភោគសាច់ដីនិតាមសេចក្តីប្រាថ្នាទាហោង ។

ទៀងនេះ បានគតិអ្នកតូចព្រមព្រៀងអាចផ្ងាញ់អ្នកធំបាន
ដូចគ្នានឹងបទបាលីក្នុងគម្ពីរលោកនីតិដែលថា ពហូនំ អប្បសារា
នំ ។ល។ ដែលបានអធិប្បាយមកហើយ ។

មួយទៀត ដីនិនោះបានគតិឆ្លុតយសទៀងបញ្ឆោរដូចគតិ
ក្អែកទៀងបញ្ឆោរសំពោច ខ្ងចនំទឹកដោះនោះឯង គួរ
ចូលចិត្តចុះ ។

**ចប់តម្រាគតិព្រមព្រៀងទី ១៧ ។ល។**

មានសត្វកណ្តុរទាំងឡាយដ៏ច្រើន អាស្រ័យនៅក្នុងទីមួយ បាន
សេចក្តីក្តៅក្រហាយលំបាកដោយមេឆ្មា ១ តែងយាយីនឹងចេញ
រកស៊ីពុំបាន ថ្ងៃមួយកណ្តុរទាំងឡាយមកប្រជុំជំនុំគ្នាថា "ពួក
យើងមានគ្នាច្រើន មេសត្រូវតែមេឆ្មា ១ គួរតែយើងស្រុះគ្នា
ចូលយុទ្ធនានឹងវាជាសត្រូវ ចោមគ្នាខាំសម្លាប់មេឆ្មានោះបង់
ចេញទើបពួកយើងបានក្តីសុខសប្បាយតទៅ" ។



ឯកណ្តុរទាំងឡាយ សឹងខ្លាចអំណាចមេឆ្មានោះមហិមា លុះឮ
ពាក្យជំនុំដូច្នោះ ក៏ពុំអាចនឹងទទួលសឹងនាំគ្នាពោលទៀងថា
"យើងវាល់គ្នាសឹងពុំហ៊ានចូលតយុទ្ធនឹងឆ្មានោះទេ" ។

គ្រាកាលនោះ មានកណ្តុរ ១ឆ្លើយទៀងថា "ខ្ញុំមានឧបាយមួយ
ល្មមនឹងរកប្រជីវិតបាន ឯឧបាយនោះ គឺថាយើងទៅរកចង្រ្កង់
បាន ១ យកមកចងកឆ្មា ថាបើទាទៅឯណាៗ យើងស្តាប់ចង្រ្កង់
ទាជាសញ្ញាគឺថាបើឮសូរចង្រ្កង់ទិសខាងកើត យើងដឹងថាមេ
ឆ្មានៅខាងកើត ហើយយើងនាំគ្នាចេញរកស៊ីទិសខាងលិច បើ
ឮខាងលិចសឹមយើងគេចទៅរកស៊ីខាងកើតវិញ ឧបាយយ៉ាង
នេះ តើអ្នកទាំងឡាយយល់ថាត្រូវខ្លះឬទេ" ។

ឯកណ្តុរទាំងឡាយ ក៏ឆ្លើយទៀងព្រមគ្នាថា "ឧបាយដែល
អ្នកគិតនេះយល់ត្រូវហើយ តែថាបើរកចង្រ្កង់បានមក តើរូប
អ្នកណាអាចក្លាហានយកចង្រ្កង់ទៅចងកឆ្មានោះបាន" ។

ឯកណ្តុរទាំងឡាយជំនុំដូច្នោះ សឹងខ្លាចពុំហ៊ានទៅចងកឆ្មា
នោះទាំងអស់គ្នា សេចក្តីជំនុំនោះក៏មិនសំរេចទៅបាន ជា
អសាឥតការទេហោង ។ ទៀងនេះបានគតិដូចរូបអ្នកតូចទាំង
ឡាយច្រើនគ្នា តើតខាត់ដោយអ្នកធំមានអំណាច មិនអាចទៅ

ធ្វើអ្វីគេបានក្តៅក្រហាយណាស់ ជំនុំតែគ្នាឯងដូចហ្ងឹងកណ្តាលជំនុំគ្នានឹងយកចង្ក្រង់ទៅចងកន្ទាយនោះឯង។ អ្នកមានបញ្ញាគួរពិចារណាមើលហោង។

**ចប់តម្រាគិតមិនស្រុះគ្នា ទី ១៨។**

មានបុរសពីរនាក់ ម្នាក់មានប្រពន្ធជាស្ត្រីកាឡកិណីម្នាក់ទៀតមានប្រពន្ធជាស្ត្រីប្រកបដោយលក្ខណា។ ជនទាំងពីរត្រកូលនោះ យកគ្នាជាមិត្រសម្លាញ់ តែងទៅមករកគ្នាជានិច្ច។ ថ្ងៃមួយចៅបុរសប្រពន្ធមានលំក្ខណ៍ ទៅបានគងមង្គលអំពីសំណាក់ទេវតា។ ឲ្យយកមកវាយ យកមាសប្រាក់ កែវកង សំពត់អាវគ្រឿងឱបភោគបរិភោគសព្វប្រការ ឯចៅមាណពប្រពន្ធខាតលំក្ខណ៍ បានដឹងថា សម្លាញ់អាត្មាកើតមានទ្រព្យសម្បត្តិដោយអំណាចគងមង្គលហើយ ទើបទៅកាន់ផ្ទះសំឡាញ់ ហើយសុំខ្ចីគងមង្គលនោះ ទៅវាយ ដើម្បីកើតមានប្រាក់កែវកងដូចគេ ឯចៅបុរសក៏ព្រមឲ្យខ្ចី ហើយមាថាសំឡាញ់ឯង យកគងយើងទៅវាយនោះ តែវាយបានតែក្នុងខណៈ ៣ ដងតែលើសអំពី ៣ដងទៅពុំបានទេ មួយទៀតចូរសំឡាញ់ឯង ទៅបទៀន ធូប ភ្លឺផ្កា គ្រឿងពីធីឲ្យល្អប្រយ័ត្នមាត់ក កុំឲ្យពោលហួសប្រមាណ ចូរអធិដ្ឋានសំដៅយកទំព្នមួយៗទើបសំរេច។



ឯចៅមាណពនោះ ក៏ទទួលពាក្យសម្លាញ់គ្រប់ប្រការ ហើយកាន់យកគងនោះលាទៅផ្ទះអាត្មា មានសេចក្តីត្រេអរនឹងបានទ្រព្យសម្បត្តិក្រៃពេកណាស់លុះទៅដល់ ក៏និយាយប្រាប់ប្រពន្ធសព្វសេចក្តីហើយប្រើប្រពន្ធទៀបគ្រឿងបូជា ឯមេកាឡកិណីព្ធប្តីប្រើឲ្យទៅទៀន ធូប លាជ ផ្កា ដូច្នោះ ក៏ពុំទទួលទកទាំងពុំមានចិត្តជឿគងមង្គលនោះផង។

ឯចៅប្តីឃើញប្រពន្ធខ្លួនពុំអើពើផងដូច្នោះ ក៏ស៊ូស្ងៀមនៅតាំងទកទៀនធូបដោយខ្លួនឯង បានហើយក៏តាំងបូជា លើកគងនោះ នឹងវាយយកមាសប្រាក់ ដល់ទំលាក់អន្លងដល់ដោះគងនោះ កាលណាមេកាឡកិណីវាស្រែកដង្ហោយទៀងថា "អង្គជាតិអើយ ចូរមកឲ្យច្រើនៗទៅ" និមិត្តតែផ្ទុតមាត់កាលណា ទីអង្គជាតិទាំងឡាយក៏កើតទៀងជាប់តាមអវយវៈរាងកាយនៃចៅប្តីនោះៗ ក៏ភិតភ័យមហិមាស្រែកហៅឲ្យប្រពន្ធជួយ។

ឯមេប្រពន្ធក៏ភិតភ័យ ទើបថា "ចូរអ្នកឯងវាយគងទៀងបណ្តេញឲ្យវាបាត់ទៅទីៗ"។ ចៅប្តីក៏ខ្ទិសថា "អង្គជាតិអើយ ចូរអន្តរធានបាត់ឲ្យអស់ទៅទីៗទៅ" ថាហើយក៏វាយគងនោះ

ជាតំរពពីរដងទៀងនិមិត្តតែផ្តុតពាក្យផ្តុតសូរគងនោះកាលណា ឯអង្គជាតិទាំងនោះ ក៏អន្តរធានបាត់ទៅវិញ មិនបាត់តែអង្គជាតិថ្មីនោះទៀយ ទាំងអង្គជាតិចាស់គឺអង្គជាតិកំណើតខ្លួនក៏បាត់ទៅទាំងអស់ បុរសស្មាបមើលដឹងថាអង្គជាតិកំណើតគឺពូជចាស់របស់ខ្លួនបាត់ទៅដងដូច្នោះក៏ប្រាប់ទៅប្រពន្ធថា គេហ៎អើយឥទ្ធរនេះពូជចាស់យើង ក៏វាបាត់ទៅជាមួយនឹងពូជថ្មីនេះហើយ"។ មេប្រពន្ធឮដូច្នោះក៏ភិតភ័យខ្លាំង ទើបប្រាប់ប្តីឲ្យទាយគងហៅអង្គជាតិកំណើត១ សម្រាប់ខ្លួនវិញ។

ឯចៅនោះក៏លើកគងទៀងវាយ និយាយថា "ត្រៀងចាស់របស់ខ្ញុំអើយ! ចូរមកកើតដូចដើមវិញ" និមិត្តតែផ្តុតពាក្យកាលណា អង្គជាតិចាស់ក៏កើតទៀងប្រាកដដូចដើមវិញហោង។

មេប្រពន្ធឃើញឥទ្ធិទ្ធិមង្គលនោះ ពូកែឆ្មុតឆាប់ដូច្នោះក៏ថា "ចូរអ្នកស្វាមីវាយទៀងម្តងទៀតទៅខ្ញុំនឹងខ្ទិសហៀយកមាសប្រាក់ ឲ្យមានដូចគេវិញ"។ ចៅប្តីថា "វាយម្តងទៀតឯណាក៏បានគងនេះវាយបាន តែត្រឹមវារ:៣ ដងឥទ្ធរឯងវាយអស់វារ:៣ដងទៅហើយ គឺវាយក្នុងកាលបឋមនោះ ហងឯងទៅពាំនាំហៀយកអង្គជាតិ វាយទីពីរនឹងតែមាត់អង្គជាតិក៏បាត់ទៅទាំង



ចាស់ទាំងថ្មី វាយទីបីហៅបានតែត្រៀងចាស់ដដែលមកវិញ នឹងវាយទី៤ ទៀតឯណាក៏បានត្រូវគេហាមផ្តាច់មកហើយ គឺតទៅមេហងឯងជាកាឡកិណី ស្ត្រីអលក្ខិកា ធ្វើឲ្យខូចពិធីអញ្ជើទៅហើយ" ថាហើយចៅនោះក៏យកគងមង្គលនោះទៅដូនម្ខាស់គេវិញហោង។

ទ្រៀងនិទាននេះ បានគតិដូចបុគ្គលគតិតការមិនស្រុះគ្នា ការឯណាមួយតែធ្វើមិនព្រមព្រៀងគ្នា ហើយការនោះមិនសម្រេចទៅបានដូចនិទានមេកាឡកិណីនោះឯង អ្នកមានសតិបញ្ញាគួរពិចារណាទៅទៀតចុះ។

**ចប់តម្រាកាឡកិណី នឹងមង្គលមិនស្រមគ្នាទី ១៩។**

មានពពែពីរតួ ដើរមកទល់ដួបគ្នានៅកណ្តាលស្ពានពពែ១ថាស្ពាននេះចំពោះដើរបានតែមួយៗ នឹងដើរច្យៀសគ្នាពុំបាន បើដូច្នោះត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណា សឹមអ្នកឯងដើរទៅចុះ។ ពពែ១ ទៀតថាយើងឯងមានការជាបន្ទាន់ ត្រូវតែអ្នកឯងថយទៅក្រោយសិន ចាំយើងដើរទៅដល់ចុងស្ពានកាលណាសឹមអ្នកឯងដើរទៅចុះ។ ពពែទាំងពីរសឹងពុំព្រមថយក្រោយដូចគ្នា កាន់មាន:ទ្រៀង

ខ្លួនក៏បោលសំទុកដល់គ្នាទុញ្ចទៅទុញ្ចមក ដោយកំលាំងទោសៈ
មោហៈ បាំងបិទឥតប្រាជ្ញានឹងសម្របគ្នា ដល់គ្នាធ្លាក់អំពីស្ថាន
ទៅក្នុងទឹកទាំងពីរតួ បាបក្តីទៃទនាដោយធ្លាក់ទឹកមានអាការ
ផ្សេងៗ។

ទៀងនេះ បានគតិដូចបុគ្គលដែលទិវាទគ្នាដណ្តើមឈ្នះទៀង
ខ្លួនចុះក្នុងកន្លួនបុរាណថា ខឹងកើតខាតមានដំកាត់ឈឺឆោត មាន
ក្តីក្រោធក្រោយក្រៀមមុខខំសំទុកធ្លាក់ទឹក ដូចនិទានពពែទាំង
ពីរនោះឯង គួរចូលចិត្តចុះ។

**ចប់តម្រារុញ្ចមិនរាជាគតិទី ២០។**

## និទាននេះមានដំណាលក្នុងកន្លួនបាវាំងសែស

មានសត្វរាជសីហ៍១ ចុះទៅផឹកទឹកស្រះកាលនោះមានសត្វ
កង្កែប១ នៅក្នុងស្រះបានឃើញរាជសីហ៍ចុះមកផឹកទឹកដូច្នោះ
ក៏ស្រែកកំហែងទៅថា "ឱ្ចរាជសីហ៍ ហេតុអ្វីចៅមកលួចផឹក
ទឹកយើងចៅសុំនរនាហៈ ស្រះនេះជាស្រះរបស់យើងគួរតែ
គំនាបយើងជាម្ចាស់ស្រះខ្លួហអ្ចះ នេះឯងព្រហើនកាចមកផឹក
មិនសុំយើងជាម្ចាស់ទៀយ"។ រាជសីហ៍ឮកង្កែបពោលមកដូច្នោះ
ក៏ទោសោខ្លាំងទើបតទៅវិញ្ចថា "ឱ្ចរអាកង្កែបតូចច្រមក់ស្រះ



នេះម៉ែ៎ឱ្ចអាឯងចែកមកប្តូទើបបានអាឯងមកពោលថាខ្លួនជា
ម្ចាស់ស្រះ ស្រះនេះហៅជាតស្រះ គឺស្រះកើតឯងតាំងពីវព្រេង
មក ជាស្រះសម្រាប់ពួកសត្វចតុប្បាទទ្វេបាទនឹងមនុស្សទាំង
ឡាយគេតែអាស្រ័យ នេះហេតុអ្វី អាឯងមកពោលកំហែង
អញ្ច ថាអញ្ចមិនគំនាប់សុំអាឯងនោះ អញ្ចចាំបាច់សុំទានអា
ឯងធ្វើអ្វី អាឯងជាម្ចាស់កាលណា នែអាកង្កែបរែមនៅគុម្ពផ្កា
អាមិនស្គាល់ប្តូទ្ចិចេស្តាអញ្ចជាស្តេចលើកប្តាលអាឯងទេប្តូ?។

កង្កែបតបថា "ឱ្ចរាជសីហ៍ ឯងអួតថាខ្លួនជាស្តេចៗមែន
ហើយ តែជាស្តេចលើសត្វចតុប្បាទខាងជើងគោក ឯអញ្ចនេះ
សោត ក៏ជាស្តេចលើសត្វខាងជើងទឹកឯទ្ចិចេស្តា អាឯងក៏មិន
លើសលែងគ្នា អញ្ចក៏ពុំកោតក្រែងប្តូទ្ចិអំណាចអាឯងប៉ុន្មាន
ប្តូអាអាឯងប្តូទ្ចិសម្រែកស្រែកឲ្យសត្វទាំងឡាយ ឮបែកក្រ
ជៀកស្លាប់នោះ ត្រង់សត្វទាំងឡាយ វាឆោតនាំគ្នាកោតខ្លាច
សម្រែករាជសីហ៍ទួទៅ ត្រង់រូបអញ្ច១ នេះមិនឆោតមិនទៅ
កោតខ្លាចសម្រែកអានោះទេ អាចង់ស្រែកយ៉ាងណាក៏អញ្ច
មិនព្រឺម"។ ឯរាជសីហ៍បានឮកង្កែបពោលពាក្យឥតក្រែង
ដូច្នោះ កិតិតថាអញ្ចនឹងបញ្ចេញន្ទវិសម្រែកឲ្យអាសត្វកង្កែប

នេះទាស្លាប់ក្នុងកាលឥឡូវនេះឯង គឺតហើយរាជសីហ៍ក៏ស្រែក
ដោយឫទ្ធិយ៉ាងខ្លាំងទៀយ ។ ឯកង្កែបកាលរាជសីហ៍ស្រែកនោះ
ទាក់លោតចាកស្លឹកឈូកមុជចុះទៅក្នុងទឹក លុះសង្រែមរាជសីហ៍
ស្លាប់បាត់ហើយ ទាក់ឆើបទៀងទំលើស្លឹកឈូកវិញ ហើយពោល
ឡកទៅថា "ទ្រីយរាជសីហ៍ឯងស្រែកអម្បាញ់មិញនេះ ឮមិន
ស្មើនឹងដោមអញផងចូរឯងស្រែកម្តងទៀតទៅមើល" ។
ឯរាជសីហ៍ទោសោខ្លាំង ក៏តាំងស្រែកទៀងលើសមុនដើម្បី
ឲ្យកង្កែបស្លាប់ ឯកង្កែបក៏មុជចុះទៅក្នុងទឹកទៀត លុះស្ងប់
សព្វរាជសីហ៍កាលណា ទាក៏ឆើបទៀងទំលើស្លឹកឈូកហើយរាំឡក
ចំអកឲ្យរាជសីហ៍ ដោយប្រការផ្សេងៗ ។ ឯរាជសីហ៍ក៏ទឹងទឹត
តែខឹងខ្លាំង តាំងប្រឹងស្រែកខ្លាំងទៀង ទាល់តែប្រេះបែកបំ
ពង់កដួលចុះដល់ន្ទូវក្តីមរណកាលក្នុងកាលនោះហោង ។ ឯកង្កែប
ឃើញរាជសីហ៍ស្លាប់ដូច្នោះ ក៏ត្រេកអរដោយសមសេចក្តី
ប្រាថ្នារបស់ខ្លួន ។

ទៀងនេះ បានគតីបុគ្គលទោសោក្រោធមិនគិតអាងឥទ្ធិឫទ្ធិ
ឥតប្រាជ្ញា មិនពិចារណាឲ្យឃើញហេតុនឹងអន្តរាយខ្លួនទៅខាងមុខ
គិតតែថាខ្លួនឯងធំ ឯងមានអំណាច កើតមាក់ងាយមើលងាយអ្នក



តូចទីនាសខ្លួនដូចសត្វរាជសីហ៍នោះហោង ។

**ចប់តម្រារោសោតតសតិសម្បជញ្ញៈទី ២១ ។**

មានសត្វទន្សាយ ១ ដើរទៅបានជួបនឹងកូនខ្លាធំពីរនៅខាង
គុម្ពឈើ ទើបសួរទោថា "ទ្រីយកូនខ្លា ថ្ងៃនេះម៉ែឯងទៅឯណា
ហើយ" ។ កូនខ្លាទាំងពីរក៏ប្រាប់ថាម៉ែយើងពុំនៅទេគាត់ចេញ
ទៅរកស៊ីពីព្រឹកមិញហើយ" ។ ឯទស្សាយក៏និយាយថា "អញ
មកនេះបើម៉ែឯងនៅអញនឹងលួងប៉ាលថ្នាំអញមើលម្តង"
ថាហើយទន្សាយ ក៏ដើរចេញទៅដល់ព្រៃស៊ុមទ្រុម មានវល្លិ
ស្អែកនោះឯង ។ ថ្លែងឯមេខ្លា ដល់ពេលល្ងាចស្រទន់ក៏ត្រឡប់
មកកាន់សំបុកកូននៃខ្លួន ដល់ហើយកូនទាំងពីរប្រាប់ថា "ម៉ែអើ
យថ្ងៃមិញនេះ អាទន្សាយទាមកពោលពាក្យអាស្សូរនោះចាក់ដៅ
តដល់ម៉ែឯង ទាថាបើម៉ែឯងនៅនេះ ទានឹងលួងប៉ាលថ្នាំទា
មើលម្តង" ។ មេខ្លាឮដូច្នោះក៏កើត ទោសោក្រោធតទន្សាយ
ដេរថាខ្មោចអាសត្វទន្សាយអប្រិយ គួរអ្វីមកស្តីពាក្យចំអាស
ឲ្យអញយ៉ាងនេះ បើដូច្នេះនឹងអត់ឲ្យទាឯណាក៏បាន គួរទៅ
តាមប្រហារទាឲ្យបង់ជីវិត គិតហើយមេខ្លាលាកូនទាំងពីរចេញ
ចាកទី ចរលីទៅតាមទន្សាយ លុះទៅដល់ព្រៃស៊ុមទ្រុមលបគន់

មើលបានឃើញទន្សាយដេកនៅនោះ មេខ្លាក៏ស្ទុះទៅដោយកំលាំងទោសោដើម្បីនឹងចាប់ទន្សាយមែកប្រហានដោយក្រចកដែង។ ឯទន្សាយ ក៏លោតគេចទៅ ខាងក្រោមវល្លិភ្នែកផ្ទុតក្រញាំងដែងខ្លាៗ លោតទៅលើស៊ុមទ្រុម ធ្លាក់ខ្លួនចុះស៊ុមទ្រុមវល្លិទៅកវល្លិភ្នែកក៏ទីតរុំជុំខ្លួននៃមេខ្លាជាប់ដែងទាំងមុខទាំងក្រោយ ខំបម្រះទៀងដោយកំលាំង។

ឯទន្សាយឃើញមេខ្លាជាប់វាមដូច្នោះ ក៏ស្ទុះទៀងពីខាងគូធនៃមេខ្លា ធ្វើអាការការលោភយហើយស្រដីថា ហ៊ុះៗឯងថាចង់ល្បែងប៉ោលថ្មលេងៗ ឥឡូវគេឲ្យឯងល្បែងប៉ោលថ្មទាល់តែបាន ទន្សាយធ្វើអាការផ្ងាលមេខ្លានោះស្រេចហើយ ក៏ស្ទុះចុះទត់ទៅកាន់ទីដទៃហោង។

ឯមេខ្លាកាលទន្សាយរត់ផ្ទុតទៅហើយ ក៏ខំទៀខ្លួនអំពីវាមស៊ុមទ្រុមនោះ បានហើយក៏ចេញមកមានសេចក្តីនឹងនឹងទន្សាយមហិមា នឹងទៅតាមចាប់វា ពេលក៏ស្រទន់ទៀបល្ងាចហើយ មេខ្លាក៏វិលត្រឡប់ទៅកាន់សំបុកខ្លួនវិញ ដល់ហើយកូនទាំងពីរក៏សួរថា "ម៉ែចទៅម៉ែ អាទន្សាយនោះម៉ែបានពីឃាតវាហើយឬ"។ មេខ្លាប្រាប់ថា "ពីឃាតវាឯណាក៏បាន ម៉ែទៅនេះសិនគេយកកែវ



ខ្មាសទៅឲ្យវាជាម្តងណ្តើយចុះ ថ្ងៃនេះឯងធ្វើការបរាជ័យចាញ់វា ចាំថ្ងៃក្រោយៗទៀតសឹមកែខ្លួនឲ្យបាន" ថាហើយមេខ្លាក៏ចូលទៅដេកបំបៅកូនក្នុងរូងនោះហោង។

ទៀងនេះ បានគតិដូចបុគ្គលខឹងហួសជ្រួសស្បៀតដល់នូវកិត្តិបរាមុខខ្លួនឯងវិញ។ មែនបុគ្គលណាខឹងហួសខឹងខ្លាំងក្លាំងសតិបញ្ញាហើយ នឹងបានក្តីក្តៅក្រហាយលើសមុនៗនោះទៀតទាល់ស្បៀតដួលខ្លួនឯងវិញ ដូចមេខ្លានេះឯង។

មួយទៀត ក្តីក្រោធនេះជាភ្លើងមែនបើឆេះទៅក្នុងទីណាហើយ ទីនោះសឹងវិនាសជាប្រាកដបុគ្គលណា កាន់ក្តីក្រោធខ្លាំងតាំងចិត្តគិតដុតអ្នកដទៃមិនឆេះទៅអ្នកដទៃឯណាទេ ចំពោះឆេះនៅក្នុងរូបបុគ្គលដែលដុតនោះឯង ភ្លើងទោសៈនេះ ដូចមេឃុំទាំងឡាយ តែខឹងខំប្រឹងទិចគេ ឯទ្រនិចឃុំនោះ តែងសណ្តកចាកគូធ មិនសណ្តកតែទ្រនិចនោះទេសណ្តកជាប់ដល់ពោះទៀនផង លោកថាឃុំណាទិចគេ ឃុំនោះអស់ទ្រនិចហើយនឹងតាំងនៅជាមេឃុំវិញពុំបាន សឹងធ្លាក់ជាតិទៅជាមេរបាមអ្នកប្រាជ្ញខ្លះថាឃុំនោះស្លាប់ខ្លួនឯង។

មួយទៀត ការផ្ងាញ់សត្រូវខ្លួនដោយក្តីក្រោធលោកនីតិថាៈ

អក្កោធេន ជិនេ កោធំ
អសាធុ សាធុនា ជិនេ
កទរិយញ្ច ទានេន
សច្ចេនាលិកវាទិនំ។

អធិប្បាយថា ឈ្នះអ្នកក្រោធដោយក្រឹត្យមិនក្រោធតប ឈ្នះអសប្បុរសប្រកបដោយសប្បុរសឈ្នះកំណាញ់ដោយឲ្យទ្រព្យរបស់ ឈ្នះបុរសទ្បើះទ្បោះដោយពាក្យសត្យ ។

មួយទៀត បុគ្គលណាកំចាត់ក្តីក្រោធបាន បុគ្គលនោះផុតក្តីក្តៅក្រហាយ ក្តីសៅសោកបានដូចបទបាលីថា៖

កោធំ វិហិត្វា ន កទាចិ សោចតិ
មក្ខប្បហានំ ឥសយោ វណ្ណយន្តិ
សព្ពេសំ ផរុសវចនំ ខមេថ
តំខន្តិ ឧត្តមមាហុ សន្តោ។

អធិប្បាយថា ជនឯណាកំចាត់ក្តីក្រោធបានជននោះគ្មានសៅសោកក្នុងលោកិយ ព្រះឥសីសរសើរ អ្នកគប្បីលះបង់ក្តីលុបគុណកបសត្យា អ្នកឯណាអាចអត់ផទុទាទ មិនរលាតដោយ



ពាក្យបេសុញ្ញា សប្បុរសសរសើរអ្នកនោះណា កបខន្តីឥតក្ខាជាខ្ពស់ត្រម ។

**ចប់តម្រាខឹងហួសជ្រួសផ្តាសបង់ខ្មាសខ្លួនឯងទី ២២។**

**ចប់ភាគទី ๕ តែប៉ុណ្ណេះ។**